# ៤. ចន្ថមានបរិស្ថាន

## ៤-១ លក្ខណៈជីវរូបសាស្ត្រ

### ៤-១-១ អាកាសធាតុ

#### ៤-១-១-១ សីតុណ្ហភាព

**១១៨.** អាកាសធាតុនៅក្នុងប្រទេសកម្ពុជាជាទូទៅមានលក្ខណៈជាអាកាសធាតុបែបសំណើមត្រូពិក ឬមូសុងត្រូពិក (Humid-Tropical or Tropical Monsoon) ជាអាកាសធាតុក្តៅ-សើម ដែលមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ។ សីតុណ្ហភាពមានលក្ខណៈខុសគ្នាតិចតួចទៅតាមអន្តរតំបន់ជាងកត្តាបរិស្ថាន និងថាវរូបបន្ត ផ្សេង១ទៀត ដែលអាចមានឥទ្ធិពល។ ភាពខុសគ្នាខ្លាំងរបស់សីតុណ្ហភាព អាចបណ្តាលមកពីទីតាំងភូមិសាស្ត្រ ពោលគឺរយៈកំពស់ដែលមានការប្រែប្រួលក្នុងចន្លោះពី ០-១៦០ម ប្រៀបធៀបនឹងនីវ៉ូសមុទ្រ **(ឧបសម្ព័ន្ធ៤-២: ផែនទី១ ផែនទីរយៈកំពស់ដី)** និងគំរបពពកដែលមានការផ្លាស់ប្តូរតាមរដូវកាល។ តាមប្រភពទិន្នន័យពី សីតុណ្ហភាពខេត្តកំពង់ធំ នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ[១] (ឆ្នាំ ២០០០-២០០៩) បង្ហាញថា ខេត្តកំពង់ធំ មានសីតុណ្ហភាពអតិបរមាគិតជាមធ្យមនៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះ ពី ៣១.៣-៣៣.៥ អង្សាសេ។ ចំណែកសីតុណ្ហភាពអប្បបរមាគិតជាមធ្យមនៅក្នុងឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ២១.៥-៣១.៣ អង្សាសេ **(ឧបសម្ព័ន ៤-១: តារាង ១, ២)**។

#### ៤-១-១-២ កំពស់ទឹកភ្លៀង

**១១៩.** ជាទូទៅអាកាសធាតុរបស់ប្រទេសកម្ពុជា មានលក្ខណៈខុសគ្នា និងមានការប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ។ ជាក់ស្តែងខ្យល់ស្ងួតបានបក់ពីភូមិភាគឦសាន្តទៅភូមិភាគនិរតីនៃប្រទេស ដោយមាននាំទាំងទឹកភ្លៀងតិចតួចមកជាមួយផង យើងហៅរដូវនេះថាជារដូវប្រាំង ហើយរដូវនេះមានរយៈពេល៦ខែ គឺចាប់ផ្តើមពីខែវិច្ឆិកា ដល់ខែមេសា។ ចំណែកឯរដូវវស្សាបានចាប់ផ្តើមពីខែឧសភា ដល់ខែតុលា ក្នុងពេលដែលខ្យល់មូសុងបានបក់ពីភូមិភាគនិរតីឆ្ពោះទៅខ្លង់រាបឦសាន្តនៃប្រទេស ដែលបាននាំមកនូវភ្លៀងដ៏ខ្លាំងដល់តំបន់ទំនាបកណ្តាល ហើយរបបទឹកភ្លៀងនេះបានជះឥទ្ធិពលដល់ការរីកលូតលាស់ និងដំណុះរបស់រុក្ខជាតិ។ តាមការអធិប្បាយរបស់លោក D.Crocker ១៩៦២ និង Anonymous, ១៩៩៧,៩៩ តំបន់ដែលទទួលភាពរាំងស្ងួតជាងគេនៅក្នុងប្រទេសកម្ពុជាគឺអាងទន្លេសាបដូចជា : តំបន់ដីទំនាបភាគខាងជើង និងខាងត្បូងនៃជួរភ្នំដងរែក ដែលភាពរាំងស្ងួតបានអូសបន្លាយរយៈពេលរហូតដល់ទៅ ០៦ខែ និងទទួលនូវរបបទឹកភ្លៀងប្រចាំឆ្នាំមានកំរិតទាបជាង ១.៤៧៧ម.ម។ តាមការសិក្សាទៅលើកំពស់ទឹកភ្លៀងដែលបានកត់ត្រានៅឯស្ថានីយ៍ ខេត្តកំពង់ធំ

[១] ប្រភព: ស្ថានីយ៍ឧតុនិយម ខេត្ត កំពង់ធំ



Draft

នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយ (២០០០-២០០៩) បានឱ្យដឹងថាមធ្យមភាគកំពស់ទឹកភ្លៀងប្រចាំឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ១.២០៦.១-១.៩៤៥.៤ ម.ម **(ឧបសម្ព័ន្ធ៤-១ តារាង៣)** ។

## ៤-១-២ ភូគព្ភសាស្ត្រ និងឋានលេខា

**១២០.** ដីនេះស្ថិតនៅតំបន់ទំនាបកណ្តាលនៃប្រទេសកម្ពុជា ស្ថិតនៅប៉ែកខាងជើងទន្លេសាប ហើយបន្តរហូតដល់ភ្នំដងរែក ទទួលរបបទឹកភ្លៀងជាមធ្យម១.៤០០-២.០០០ម.ម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំស្ថិតក្នុងចន្លោះ ២៦.៥៤-២៦.៨៨ដឺក្រេសែលស៊ុស ដែលរដូវប្រាំងមានរយៈពេលច្រើនជាង៤ខែ (DANIDA, 2003)។ នៅរដូវវស្សាតំបន់នេះចាប់ផ្តើមមានភ្លៀងធ្លាក់នៅដើមខែឧសភា ឋានលេខារបស់ដីសម្បទាននេះមានលក្ខណៈរាបស្មើ។ ជាទូទៅដីស្រទាប់លើ (០-២០ស.ម) មានពណ៌លឿង ភាគច្រើនសម្បូរណ៍គ្រួសតូចៗ មានអង្កត់ផ្ចិតពី០,០២-១,០ស.ម មានពណ៌លឿងហើយផុយស្រួយ ជាដីដែលខ្សត់សារជាតិខនិក ដោយសារតែកឺតជំរាបខ្ពស់។ នៅក្នុងជម្រៅពី ២០-៤០ស.ម ដីមានពណ៌លឿងហើយម៉ត់ មានលាយល្បាយខ្សាច់មានគ្រាប់គ្រើមបង្គួរ កន្លែងខ្លះមានដុំថ្មធំៗ (លឿង-ប្រផេះ តែផុយស្រួយ) ដែលមានទំហំពី ១,០-៤,០ស.ម។ នៅក្នុងជម្រៅពី ៤០-៦០ស.ម មានវាយនភាពជាដីឥដ្ឋល្បាយខ្សាច់ មានពណ៌លឿងចាស់ កន្លែងខ្លះក្រហម-ក្រម៉ៅ។ ដីនៅតាមជំរាលអូរ និងពោះអូរ មានវាយនភាពជាដីល្បាយខ្សាច់ពណ៌ប្រផេះក្រម៉ៅ សម្បូរណ៍កំទិចកំណរសារធាតុសរីរាង្គ-ពពួកមមោត (ស្លឹកនិងកំទិចឈើ) ដែលកើតឡើងពីការពុកផុយនៃរុក្ខជាតិជាយូរឆ្នាំ។ នៅរដូវប្រាំងស្ថានភាពដីតំបន់នេះ មានភាពងាយស្រួលក្នុងការធ្វើដំណើរ និងការដឹកជញ្ជូនផល-អនុផលព្រៃឈើ។

**១២១.** ដីជាតិអាចកំណត់ដោយសិលាមេដែលមានស្ថិតនៅស្រទាប់ក្រោម លក្ខណៈគីមីរបស់ដីតែងតែបញ្ជាក់អំពីកឺតនិងលំនាំនៃការបំបែកធាតុរបស់សិលាមេក្នុងយុគសម័យភូគព្ភសាស្ត្រ និងលក្ខណៈរបស់ថ្មដែលជាសិលាមេ។ ដំណើរប្រព្រឹត្តទៅនៃបាតុភូតភូគព្ភសាស្ត្រនេះបានទទួលរងនូវឥទ្ធិពលអាកាសធាតុ ពេលវេលា ឋានលេខា និងដំណើរប្រព្រឹត្តទៅតាមលក្ខណៈជីវសាស្ត្រធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្វ និងបាក់តេរី។ កត្តាទាំងអស់នេះអាចបញ្ជាក់ដោយផ្ទាល់ និងដោយប្រយោលអំពីដីដែលមានលក្ខណៈជាអាស៊ីតពណ៌ រចនាសម្ព័ន្ធ ជីជាតិ លទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក។ យោងតាមផែនទីភូគព្ភសាស្ត្របានបង្ហាញថាដីរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** មានសិលាមេ ០៤ ប្រភេទ រួមមាន : (១)- Lake bed deposits មានចំនួន ១០ហិកតា ស្មើនឹង ០,១២ភាគរយ (២) - Pediments មាន ៣២៣ហិកតា ស្មើនឹង ៣,៩៩ ភាគរយ (៣)- Peneplain laterite deposits ៧.៧៤៨ ហិកតា ស្មើនឹង ៩៥,៦៥ ភាគរយ និង (៤)- Phtanite មាន ១៩ ហិកតា ស្មើនឹង ០,២៣ ភាគរយ នៃផ្ទៃដីសរុប **(ឧបសម្ព័ន្ធ៤-២: ផែនទី២ ផែនទី ភូគព្ភសាស្ត្រ និងឋានលេខា)** ។

Draft

**តារាង ៤-១: ចំណាត់ថ្នាក់ប្រភេទសិលាមេនៅក្នុងតំបន់គំរោងអភិវឌ្ឍន៍**

| **ប្រភេទសិលាមេនៅក្នុងតំបន់សម្បទាន** | **ផ្ទៃដី (ហិកតា)** | **ភាគរយ** |
|---|---|---|
| **Lake bed deposits** | ១០ | ០,១២ |
| **Pediments** | ៣២៣ | ៣,៩៩ |
| **Peneplain laterite deposite** | ៧.៧៤៨ | ៩៥.៦៥ |
| **Phtanite** | ១៩ | ០,២៣ |
| **សរុបរួម** | ៨.១០០ | ១០០ |

### ៤-១-៣ ចំណាត់ថ្នាក់ប្រភេទដីនៅក្នុងតំបន់គំរោងអភិវឌ្ឍន៍

**១២២.** យោងតាមលក្ខណៈដីនិងឋានលេខាដីរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** មានដី ៣ប្រភេទ គឺ : (១) - Grey Hydromorphics មានទំហំ ៣៨៤៦ ហិកតា ស្មើនឹង ៤៧,៤៨ ភាគរយ នៃផ្ទៃដីសរុប នៅពាក់កណ្ដាលជ្រុងខាងលិចឈាងខាងជើង សណ្ដូកពីទិសខាងលិចទៅកើត (២) -Lacustrine Aliuvial Soils មានទំហំ ៣៣២ ហិកតា ឬស្មើនឹង ៤,១០ ភាគរយ ស្ថិតនៅជ្រុងពយជាប់ព្រំប្រទល់ខាងលិចឈាងខាងត្បូងក្នុងតំបន់ដីសម្បទាន និង (៣)-Red-yellow podzols មានទំហំ ៣៩២២ ហិកតា ឬស្មើនឹង ៤៨,៤២ ភាគរយ ស្ថិតនៅគ្របដណ្ដប់ពាក់កណ្ដាលទៅផ្នែកខាងកើតឈាងខាងត្បូង **(ឧបសម្ព័ន្ធ៤-២ ផែនទី៤ ផែនទីចំណាត់ថ្នាក់ប្រភេទដី)** ។

**១២៣.** យោងតាមរបាយការណ៍របស់លោក D. Crocker ក្នុងឆ្នាំ ១៩៦២-៦៣ នៅក្នុងរយៈពេលនៃការធ្វើអង្កេតលើលក្ខណៈអេកូឡូស៊ីដែលបានប្រព្រឹត្តទៅពេលថ្មី១នេះ ភាគច្រើននៃប្រភេទរបស់ដីនៅក្នុងតំបន់ដីសម្បទានបានរក្សាទុកនូវសភាពដើមដោយគ្មានអ្វីប្រែប្រួលគួរឱ្យកត់សំគាល់ឡើយ បើប្រៀបធៀបជាមួយនឹងរបាយការណ៍របស់លោក D.Crocker លើកលែងតែការផ្លាស់ប្តូរមួយផ្នែកតូចប៉ុណ្ណោះដែលកើតមានជាពិសេសចំពោះដីល្បប់។ ការប្រែប្រួលនេះអាចធ្វើការបកស្រាយបានដោយយោងទៅលើមូលហេតុនៃទឹកជំនន់ទៅតាមរដូវនៅក្នុងតំបន់ទំនាបរបស់ដីសម្បទាន។ យោងទៅលើលក្ខណៈដើម និងលក្ខណៈនៃឋានលេខា យើងអាចបែងចែកប្រភេទដីដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម :

Draft

**តារាង ៤-២ : ចំណាត់ថ្នាក់ប្រភេទដីនៅក្នុងតំបន់គំរោងអភិវឌ្ឍន៍**

| ប្រភេទដីនៅក្នុងដីសម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| Grey Hydromorphics | ៣.៨៤៦ | ៤៧,៤៨ |
| Lacustrine Alluvial Soils | ៣៣២ | ៤,១០ |
| Red-yellow podzols | ៣.៩២២ | ៤៨,៤២ |
| **សរុបរួម** | **៨.១០០** | **១០០** |

**១២៤.** តាមការធ្វើចំណាត់ថ្នាក់ដីរបស់ក្រសួងកសិកម្ម ប្រភេទដី Grey Hydromorphics មានសក្តានុពលទាប សម្រាប់ការធ្វើកសិកម្ម ជាពិសេសចំពោះដំណាំរួមផ្សំនៅទីទួលខ្ពស់ៗ មានជីជាតិមធ្យមត្រូវមានការកែប្រែសំរាប់ដំណាំស្រូវ ដោយប្រពនធារាសាស្ត្រទើបជាការប្រសើរ បើពុំនោះទេ គួរតែជាតំបន់បំរុងទុកដាំដុះព្រៃឈើឡើងវិញ។ យកល្អដោយចំពោះ Red-Yellow Podzols វិញ ក៏ជាដីដែលមានវាយនភាពងាយទទួលរងការជ្រាបខ្ពស់ ដូច្នេះការប្រែក្លាយដីព្រៃប្រភេទនេះសម្រាប់ដាំដំណាំរួមផ្សំ មិនមានអំណោយផលល្អទេព្រោះប្រឈមមុខនឹងការផ្តល់ជីបន្ថែមច្រើន ត្រូវដាំដុះព្រៃឡើងវិញ ឬអភិវឌ្ឍជាវាលស្មៅទើបល្អ។ ហើយ Lacustrine Alluvial Soils ដីមានជីជាតិត្រូវប្រើជីផូស្វាតដើម្បីបង្កើនទិន្នផលខ្ពស់ ជាមួយនិងប្រពន្ធ័ធារាសាស្ត្រទប់ទឹកជំនន់ ***(ឧបសម្ព័ន្ធ ៤-៣ :តារាងបែងចែក ចំណាត់ថ្នាក់ប្រភេទដីរបស់ក្រសួងកសិកម្ម )*** ។

## ៤-១-៤ ចំណាត់ថ្នាក់ជីជាតិដី

**១២៥.** យោងតាមចំណាត់ប្រភេទគុណភាពជីជាតិរបស់ដី នៅក្នុងតំបន់សម្បទានទាំងមូលមាន២ប្រភេទ (តារាង ៤-៣) គឺមានជីជាតិខ្ពស់មានទំហំ ៤.១៨៣ ហិកតា ឬស្មើនឹង ៥១.៦៤ ភាគរយ លាតសន្ធឹងពីលិចទៅកើតរូចបត់ទៅជើងតាមរាងដី និងមានមួយផ្នែកតូចស្ថិតនៅចំពយត្រង់ជ្រុងខាងត្បូង ដែលគ្របដណ្តប់ជាងពាក់កណ្តាលដីសម្បទានទាំងមូល ចំណែកដីមានជីជាតិទាបមានទំហំ ៣.៩១៧ ហិកតា ឬស្មើនឹង ៤៨.៣៩ ភាគរយ ចាប់ពីពាក់កណ្តាលកែងលាតសន្ធឹងមកខាងកើតឈាងខាងត្បូងផ្ទៃដីសម្បទាន **(ឧបសម្ព័ន្ធ ៤-២ ផែនទី៩ ផែនទីជីជាតិដី)** ។

**តារាង ៤-៣ : ចំណាត់ថ្នាក់ជីជាតិដីនៅក្នុងតំបន់គំរោងអភិវឌ្ឍន៍**

| ចំណាត់ថ្នាក់ជីជាតិដីនៅក្នុងតំបន់សម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| High productivity Soil | ៤.១៨៣ | ៥១,៦៤ |
| Low Productivity Soil | ៣.៩១៧ | ៤៨,៤២ |
| **សរុបរួម** | **៨.១០០** | **១០០** |

### ៤-១-៥ ចំណាត់ថ្នាក់ទីជំរាល

**១២៦.** យោងតាមការអង្កេតលើចំណាត់ថ្នាក់ទីជំរាល (Slope Classification) បានលេខារបស់ដីសម្បទាននេះមានលក្ខណៈមិនរាបស្មើ និងមានចំណាត់ថ្នាក់ទីជំរាល ០៥ប្រភេទគឺ:

- **ចំណាត់ថ្នាក់ ០-២ ដឺក្រេ :** ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់០-២ដឺក្រេ មានចំនួន ៧.៦៤៨ ហិកតា ស្មើនឹង ៩៤.៤២ ភាគរយ នៃផ្ទៃដីសរុប ជាដីដែលមានសណ្ឋានរាបស្មើ។ ផ្អែកលើទស្សនៈនៃការអភិរក្ស ទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ មិនមានតម្រូវការនៃការអភិរក្សទឹក និងដីទេ ហើយការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ព្រោះវាជាដីដែលមានសណ្ឋានស្ទើររាបស្មើ។ ដូច្នេះដីតំបន់នេះអាចប្រើប្រាស់សម្រាប់ដំណាំកសិកម្ម និងព្រៃឈើ។

- **ចំណាត់ថ្នាក់ ២-៥ ដឺក្រេ :** ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់ ២-៥ដឺក្រេមានចំនួន ៤០២ ហិកតា ស្មើនឹង ៤.៩៦ ភាគរយ នៃផ្ទៃដីសរុប។ ដីតំបន់នេះមានលក្ខណៈស្ទើររាបស្មើ ហើយមិនមានតម្រូវការនៃការអភិរក្សទឹក និងដីទេ។ ដូច្នេះដីនៅតំបន់ទីជំរាលប្រភេទនេះ អាចប្រើប្រាស់សម្រាប់ដំណាំកសិកម្ម និងព្រៃឈើ។

- **ចំណាត់ថ្នាក់ ៥-១០ដឺក្រេ:** ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់ ៥-១០ដឺក្រេ មានចំនួន ៣១ហិកតា ស្មើនឹង ០,៣៨ ភាគរយនៃផ្ទៃដីសរុប។ ដីតំបន់នេះមានលក្ខណៈចោតបន្តិចម្តងៗ ហើយ សណ្ឋានដីមានលក្ខណៈច្រោះទាបជាងចំណាត់ថ្នាក់ទាំង២ខាងលើ។ សណ្ឋានដីប្រភេទនេះ តែងជួបប្រទះនៅផ្នែកជើង និងខាងកើតឈាងត្បូងដីស្ទើសុំ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹកនិងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមាន លក្ខណៈទូលំទូលាយហើយធន់នឹងការហូរច្រោះជាងចំណាត់ថ្នាក់ទាំង២ខាងលើ។ ការប្រើប្រាស ដីតំបន់នេះអាចមានលក្ខណៈជាការដាំឈើបែបផែនពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម ប្រសិនបើអនុវត្តវិធានការណ៍អភិរក្សបានត្រឹមត្រូវ។

- **ចំណាត់ថ្នាក់ ១០-២០ដឺក្រេ:** ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់ ១០-២០ដឺក្រេ មានចំនួន ១០ហិកតា ស្មើនឹង ០,១២ ភាគរយ នៃផ្ទៃដីសរុប។ ដីតំបន់នេះមានចំណោតចោតល្មម ហើយជា ធម្មតាតែងជួបប្រទះនៅតំបន់ខ្ពង់រាប។ សណ្ឋានដីប្រភេទនេះមានលក្ខណៈងាយរងភាពរេចរិលទឹក និងដីទាបជាងទីជំរាលចំណាត់ថ្នាក់ខាងលើ។ ដីតំបន់នេះត្រូវបានប្រើប្រាស់សម្រាប់ការអភិរក្ស និង/ឬព្រៃផ្តល់ផល Agro-Forestry និងវាលស្មៅប្រសិនបើអនុវត្តវិធានការណ៍អភិរក្សបានខ្ជាប់ខ្ជួន។

- **ចំណាត់ថ្នាក់ធំជាង២០ដឺក្រេ:** ដីសម្បទានតំបន់នេះមានដីជំរាលចំណាត់ថ្នាក់ធំជាង២០ដឺក្រេ មានចំនួន ៩ ហិកតា ស្មើនឹង ០.១១ ភាគរយ នៃផ្ទៃដីសរុប។ ដីតំបន់នេះមានចំណោតចោតខ្លាំង ហើយជាធម្មតាតែង ជួបប្រទះនៅតំបន់ខ្ពង់រាប។ សណ្ឋានដីប្រភេទនេះមានលក្ខណៈងាយរងភាពរេចរិលទឹក និងដី។ ដីតំបន់



Draft

នេះត្រូវបានប្រើប្រាស់សម្រាប់ការអភិរក្ស និង/ឬព្រៃផ្តល់ផល Agro-Forestry និងវាលស្មៅប្រសិនបើអនុវត្តវិធានការណ៍អភិរក្សបានខ្ជាប់ខ្ជួន។ (**ឧបសម្ព័ន្ធ៤-២ ផែនទី៦ ផែនទីចំណោត់ថ្នាក់ទីជំរាល**)

**តារាង ៤-៤ : ចំណោត់ថ្នាក់ទីជំរាលដីនៅក្នុងតំបន់គំរោងអភិវឌ្ឍន៍**

| ចំណោត់ថ្នាក់ទីជំរាលដីនៅក្នុងតំបន់សម្បទាន | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|
| $0^{0}$ - $២^{0}$ | ៧.៦៤៨ | ៩៤.៤២ |
| $២^{0}$ - $៥^{0}$ | ៤០២ | ៤.៩៦ |
| $៥^{0}$ - $១០^{0}$ | ៣១ | ០.៣៨ |
| $១០^{0}$ - $២០^{0}$ | ១០ | ០.១២ |
| ធំជាង $២០^{0}$ | ៩ | ០.១១ |
| **សរុបរួម** | **៨.១០០** | **១០០** |

### ៤-១-៦ ទឹកស្រទាប់លើ និងគុណភាពទឹក

**១២៧.** ទឹកស្រទាប់លើៈ នៅតំបន់ដីសម្បទាននេះប្រភពទឹកស្រទាប់លើមានមធ្យម។ ដោយសារថា នៅផ្នែកខាងត្បូងនៃតំបន់ដីសម្បទាន និងផ្នែកខាងត្បូងឈាងខាងកើតមាន**ស្ទឹងជីនីត** ហូរកាត់កៀរ ហើយដោយឡែកផ្នែកខាងជើង និងខាងលិចនៃតំបន់សម្បទាន ក៏មានប្រភពទឹកស្រទាប់លើបានមកពីអូរ ព្រៃកធម្មជាតិមួយចំនួនដូចជា : អូរបឹងសំរោង អូរកំបោរ អូរកំបោររលួស និងជាមួយអូរត្រពាំងឈូក។ ក្រៅពីអូរទាំងបួននេះចេញ គេសង្កេតឃើញមានត្រពាំងចំនួន០១ គឺត្រពាំងឈូក និងអូរតូចៗចំនួនពីរទៀតដែលមិនមានឈ្មោះនៅក្នុងផែនទី តែអូរតូចៗទាំងនេះមួយចំនួនត្រូវបានរីងអស់នៅចុងរដូវប្រាំង។ ពាក់ព័ន្ធទៅនឹងប្រភពទឹកនៅក្នុងតំបន់ទីតាំងគំរោង ទឹកស្រទាប់លើមានប្រភពហូរមកពីប៉ែកខាងលើ គឺភាគខាងជើងនៃទីតាំងគំរោងឆ្ពោះទៅប៉ែកខាងត្បូងនៃទីតាំង និងមួយផ្នែកទៀតហូរពីទិសខាងលិចទៅទិសខាងកើត រួចបន្តហូរចូលទៅក្នុងប្រភពទឹកស្ទឹងជីនីត មុននឹងបន្តហូរចូលទៅក្នុងបឹងទន្លេសាប។

**១២៨.** ប្រភពដែលអាចបង្កនៃភាពក្រខ្វក់ដល់ទឹកៈ បច្ចុប្បន្នមិនមានការបំពុលទឹកអ្វីគួរអោយចាប់អារម្មណ៍នៅក្នុងតំបន់នោះទេ តែនៅថ្ងៃអនាគតប្រភពដែលអាចបង្កឱ្យមានភាពក្រខ្វក់ដល់ទឹកអាចកើតមានឡើងបានពីសកម្មភាពឈូសឆាយរានដីចំនួន ៧.២៨៩ហិកតា ដើម្បីដាំដំណាំកៅស៊ូ នៅក្នុងករណីដែលប្រតិបត្តិការដាំដុះមិនបានអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថានបានត្រឹមត្រូវ។

**១២៩. ការយកសំណាកទឹក និងការវិភាគ :** ក្រុមការងារបានយកសំណាកទឹក ០២កន្លែង (ទឹកអណ្តូងផ្ទះប្រជាពលរដ្ឋ និងទឹកអូរកំបោរ) កាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១១ នៅត្រង់ចំណុចនិយាមកា

Draft

<u>(X=548480 ; Y=1387963) ស្ថិតនៅក្នុងទីតាំងដីក្រុមហ៊ុន តាន បៀន ក្នុងឃុំក្រយា ស្រុកសន្ទុក និង សំណាកទឹកអណ្តូងលូ ត្រង់ចំណុចនិយាមកា (X=548480 ; Y=1387963) ដែលស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ដើម្បីធ្វើការវិភាគអំពីលក្ខណៈរូបនិងលក្ខណៈគីមី ។ សំណាកនេះត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍ របស់ក្រសួង បរិស្ថាន ដើម្បីធ្វើការវិភាគ ។</u>

**១៣០.** តាមរយៈលទ្ធផលនៃការវិភាគគុណភាពទឹកក្នុង**<u>សំណាកទឹកទី១</u>** ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានបាន បង្ហាញថា **(១)-លក្ខណៈរូប** - នៅក្នុងចំណោមថាវរូបវន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននេះ មានទាបជាងកំរិតស្តង់ដាររបស់ទឹកផឹក និង Total Bacteria មានកំរិតខ្ពស់ជាងបន្តិច ដែលត្រូវបានអនុញ្ញាត អោយប្រើប្រាស់របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអង្គការសុខភាពពិភពលោក ពោលគឺ 0/0 ចំពោះ Total Coliform និង ១៦០/១០០ ចំពោះ Total Bacteria **(២) លក្ខណៈគីមី**-នៅក្នុងចំណោម ថាវរូបទាំង២០ មានវត្តមាន ថាវរូបចំនួន០៤ ដែលជា Trace Metals (Nickel, Cobalt, Cadmium and Mercury) ដែលក្នុងករណី ធម្មតាថាវរូបទាំងនេះមិនមាននៅក្នុងទឹកបរិភោគទេ។ ចំណែកឯថាវ រូបចំនួន១៦ ផ្សេងទៀតមិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ ដែលស្ថិតនៅក្នុងកំរិត pH ៦.៩៧ (**ឧបសម្ព័ន្ធ ៤-៥ :** <u>តារាងទី១ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ៥៤ ពសវភ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១)</u> ។

**១៣១.** តាមរយៈលទ្ធផលនៃការវិភាគគុណភាពទឹកក្នុង**<u>សំណាកទឹកទី២</u>** ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថានបាន បង្ហាញថា **(១) លក្ខណៈរូប** - នៅក្នុងចំណោមថាវរូបវន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននេះ មានខ្ពស់ជាងកំរិតស្តង់ដាររបស់ទឹកផឹកដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និងអង្គការសុខភាពពិភពលោក ពោលគឺ ២.៣ x $១០^{២}$/<១០០០ ចំពោះ Total Coliform និង ៣៨០/០ ចំពោះ Total Bacteria និង ចំពោះ Total Coliform **(២) លក្ខណៈគីមី** - នៅក្នុងចំណោមថាវរូបទាំង២០ មានវត្តមាន ថាវរូបចំនួន០៤ ដែលជា Trace Metals (Nickel, Cobalt, Cadmium and Mercury) ដែលក្នុងករណី ធម្មតាថាវរូបទាំងនេះមិនមាននៅក្នុងទឹកបរិភោគទេ។ ចំណែកឯថាវ រូបចំនួន១៦ ផ្សេងទៀតមិនមានអ្វីគួរអោយ ធ្វើការកត់សំគាល់ទេ ដែលស្ថិតនៅក្នុងកំរិត pH ៦.៨៥ (**ឧបសម្ព័ន្ធ ៤-៥ :** <u>តារាងទី១ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថានលេខ ៥៥ ពសវភ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១)</u> ។

Draft

## ៤-២ ធនធានអេកូឡូស៊ី

### ៤-២-១ សហគមន៍សារព័ន្ធរុក្ខជាតិ និងការប្រើប្រាស់ដី

#### ៤-២-១-១ សហគមន៍សារព័ន្ធរុក្ខជាតិ

**១៣២.** កំណើតដើមនៃប្រភេទព្រៃទាំងនៅក្នុងតំបន់សម្បទាននេះ គឺអាស្រ័យទៅនឹងអាកាសធាតុរបស់តបន់ លក្ខណៈភូមិសាស្ត្រ សណ្ឋានដី និងសមាសភាពនៃប្រភេទឈើ ហើយប្រភេទព្រៃសំខាន់ៗ ទាំងនេះបានកើតឡើង ដោយសារអនុប្រភេទជាច្រើនទៀត។ ឯកសារយោងដែលបានប្រើជាមូលដ្ឋាននៅក្នុងរយៈពេលនៃការសិក្សា និងអង្កេតក្នុងតំបន់នេះ គឺរូបភាពផ្កាយរណបរបស់ MRC GIS Dataset ឆ្នាំ១៩៩២-១៩៩៣, MRC GIS Dataset ឆ្នាំ១៩៩៧, FA GIS Dataset ឆ្នាំ ២០០២ និង ២០០៦ របស់រដ្ឋបាលព្រៃឈើ **(ឧបសម្ព័ន្ធ ៤-២ : ផែនទីទី៧ ដល់១០ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ)**។ នៅក្នុងរយៈពេលនៃការវាយតំលៃអំពីអេកូឡូស៊ី និងពាណិជ្ជកម្មរបស់ព្រៃបានបញ្ជាក់ថា ស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់នេះត្រូវទទួលរងការខានធ្ងន់ធ្ងរ។ ឈើដែលមានតម្លៃពាណិជ្ជកម្ម ត្រូវបានដកហូតស្ទើរតែទាំងស្រុងហើយ។ ការសិក្សាអំពីការប្រែប្រួលស្ថានភាព សារពើរុក្ខជាតិក្នុងតំបន់សម្បទាននេះ ក្នុងចន្លោះឆ្នាំ ១៩៩២-២០០៦ បានបង្ហាញថា:

- **ឆ្នាំ១៩៩២-១៩៩៣:** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិពីរប្រភេទគឺ : មានគំរបព្រៃឈើ និងដីព្រៃគុម្ពោត។
- **ឆ្នាំ១៩៩៦-១៩៩៧ :** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបីប្រភេទគឺ : មានគំរបព្រៃឈើ និងដីកសិកម្ម។
- **ឆ្នាំ២០០២:** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបីប្រភេទ: ព្រៃស្រោង ដីវាលស្មៅ និងដីព្រៃគុម្ពោត។
- **ឆ្នាំ២០០៦:** តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបីប្រភេទគឺ : ព្រៃស្រោង ព្រៃផ្សេងៗ និងដីគ្មានគំរបព្រៃ។

### ៤-២-២ ស្ថានភាព និងការប្រែប្រួលរបស់គំរបព្រៃ

**១៣៣.** តាមរយៈការវិភាគ អំពីការប្រែប្រួលអំពីស្ថានភាពរបស់គំរបព្រៃក្នុងតំបន់ដែនសម្បទានទាំងមូល នៅក្នុងរយៈពេល១៤ឆ្នាំ **(ឧបសម្ព័ន្ធ៤-២ : ផែនទី៦-១០)** ចុងក្រោយដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់ MRC GIS Dataset, 1992-93, 1997, FA GIS Dataset ២០០២ និង ២០០៦ បានបង្ហាញអោយដឹងថា ស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃមានការប្រែប្រួលគួរអោយចាប់អារម្មណ៍។ ដំណើរការបំរែបំរួលនេះ មានបង្ហាញជូននៅក្នុងតារាង ៤-៥ ខាងក្រោម :



Draft

**តារាង ៤-៥: ការបង្ហាញអំពីដំណើរប្រែប្រួលស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃរយៈពេល១៤ឆ្នាំ**

| ប្រភេទព្រៃ | ១៩៩២-៩៣ | ១៩៩៧ | ២០០២ | ២០០៦ |
|---|---|---|---|---|
| ដីមានគំរបព្រៃ | ៨០៨៣ | ៧៩៦៧ | | |
| ព្រៃស្រោង | | | ៧៧៦៩ | ៧៩៥៥ |
| ព្រៃគុម្ពោត | ១៧ | ១២១ | | |
| ដីព្រៃផ្សេងៗ | | | ២៩៧ | ៣៨ |
| ដីវាលស្មៅ | | ១២ | | |
| ដីគ្មានគំរបព្រៃ | | | ៧៤ | ១០៧ |

## ៤-២-៣ ប្រព័ន្ធមជ្ឈដ្ឋានហ៊ៀរបស់តំបន់ទំនាបកណ្ដាល

**១៣៤.** ដីគំរោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន TAN BIEN KAMPONG THOM APHIVATH CAOUT CHOUC CO., LTD. មានប្រព័ន្ធមជ្ឈដ្ឋានហ៊ៀនស្ថិតនៅក្នុងតំបន់ទំនាបកណ្ដាល ដែលក្នុងនោះរាប់បញ្ចូលទាំងតំបន់ផលិតកម្មកៅស៊ូ សំខាន់ៗ ហើយបង្កើតបានជាប្រព័ន្ធមជ្ឈដ្ឋានហ៊ៀនរបស់តំបន់ទំនាបកណ្ដាលធំជាងគេ (១៨ភាគរយ) ។ តំបន់ ទំនាបនេះគឺអាងស្តុកទឹកសំខាន់មុនហូរចាក់ចូលទៅក្នុងទន្លេសាប និងទន្លេមេគង្គ។ តំបន់នេះផ្នែកខាងត្បូង បញ្ចប់នឹងតំបន់ដីក្រហម ខាងជើងជាប់នឹងភ្នំដងរែក ខាងលិចជាប់នឹងតំបន់ទំនាបខាងជើង និងខាងកើតជាប់នឹងតំបន់ទំនាបទន្លេមេគង្គផ្នែកខាងកើត។ តំបន់នេះមានលក្ខណៈខុសពីតំបន់ដីទៃទៀតដោយសារកំពស់ទឹកភ្លៀងទាប ហើយដីមានប្រភេទដីដូចៗគ្នា។

**១៣៥.** ប្រព័ន្ធមជ្ឈដ្ឋានហ៊ៀនរបស់តំបន់នេះអាចកំណត់បានតាមរយៈរបបទឹកភ្លៀងទាប (១៤០០-២០០០ម.ម) និងដីដែលមានប្រភេទដូចគ្នា។ ខុសពីប្រព័ន្ធមជ្ឈដ្ឋានហ៊ៀនតំបន់ពាយ័ព្យ ដែលភាគច្រើនគ្របដណ្ដប់ទៅដោយដីជីជាតិ ដែលមានអាយុផ្សេងៗគ្នា។

**១៣៦. លក្ខណៈរបស់រុក្ខជាតិ និងសារព័ន្ធរបស់វា:** ឈើពាណិជ្ជកម្មសំខាន់ៗ នៅក្នុងព្រៃបៃតងជានិច្ច ដែលដុះនៅតំបន់ទំនាបភាគច្រើនស្ថិតនៅក្នុងប្រភេទ *Albizia lebbeck* (L) Benth., *Afzelia xylocarpa* (Kurz) Craib., *Cananga Latifolia* (Hook .F. & Thomson) Finet and Gagnep (one source), *Cinnamomum cambodianum* Lecompte, *Dalbergia chochinchinense* Pierre (one source), *Dalbergia oliveri* Gamble, *Dasymascalon lamantaceum* Finet at Gagnep (one source), *Dyospiros cruenata* Thwaites, *Hopea helferi* (Dyers) Brandis (one source), *Pterocarpus Macrocarpus* Kurz, *Shorea Cochinchinense* Pierre, *Sterculia lycnophora* Hance ។

Draft

### ៤-២-៤ លំនាំនៃការប្រើប្រាស់ដី

**១៣៧.** ជាច្រើនជំនាន់មកហើយរាល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រទេសមួយផ្នែកធំ គឺផ្អែកលើកសិកម្ម ដែលបានប្រមូលផ្តុំនៅជុំវិញតំបន់ទំនាបទន្លេមេគង្គ។ ដំណាំកសិកម្មដែលមានគឺ : ស្រូវ កៅស៊ូ សណ្តែក កប្បាស ពោត អំពៅ ម្នាស់ និងបន្លែផ្សេងៗទៀត។ ប៉ុន្តែថ្មីៗនេះសង្កេតឃើញមានការរីកដុះដាលនូវចលនា នៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្មជាច្រើន ដែលជាទិសដៅរបស់ រដ្ឋាភិបាលនៅក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ តាមរយៈការទាក់ទាញវិនិយោគិនឱ្យធ្វើការវិនិយោគ នៅក្នុងវិស័យកសិកម្ម។

**១៣៨.** គួរឱ្យកត់សំគាល់ផងដែរថា ការផ្លាស់ប្តូរនូវលំនាំនៃការប្រើប្រាស់ដីនៅក្នុងប្រទេសយើង គឺកើតមាន ឡើងដោយសារហាយនភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ក្នុងរយៈពេលនៃបណ្តាឆ្នាំដែលសង្គ្រាមស៊ីវិល បានអូសបន្លាយរ៉ាំរ៉ៃ ក្នុងនោះផ្ទៃដីមួយភាគធំត្រូវបានបោះបង់ចោល ហើយបន្ទាប់មកក៏ក្លាយទៅជាដីដែល គ្មានជីជាតិ។ គ្រោះមហន្តរាយដែលកើតមានឡើងកន្លងមកបានជំរុញឱ្យមានការផ្លាស់ប្តូរ ទីកន្លែងរស់នៅរបស់ ប្រជាជនជនបទឆ្ពោះទៅតំបន់ខ្ពង់រាប ដើម្បីប្រកបរបរនិងផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគាត់។ ជាលទ្ធផល យន្តការនេះបាននាំមកនូវកំណើននៃសម្ពាធទៅលើធនធានធម្មជាតិ (ព្រៃឈើ) ហើយនឹងការរីកដាលបន្តិច ម្តងៗ ឆ្ពោះទៅរកតំបន់ភ្នំដោយសារការធ្លាក់នូវធនធានព្រៃឈើនៅក្នុងតំបន់ទំនាប។

Draft

### ៤-៣ ការពិនិត្យ និងវាយតំលៃស្ថានភាពធនធានព្រៃឈើលើរូបភាពថតពីអាកាសដោយប្រើ Paramotor

**១៣៩.** តាមរយៈរូបភាព Photo Index Maps នៅលើចំណុចទាំង១៦ (**ឧបសម្ព័ន្ធ៤-៦:** Photo Index A, B, C, D, E, F, G, H, I, J, K, L, M, N, O, P) បង្ហាញអោយឃើញថា គំរបព្រៃនិងធនធាន ព្រៃឈើមានលក្ខណៈជាព្រៃស្រោង ដែលទទួលរងការរំខានធ្ងន់ធ្ងរ ឬអាចយល់បានថាជាព្រៃផ្សេងៗ ដែលរេច រឹល ចំណែកឯដីដែលគ្មានព្រៃ គឺជាដីដែលក្រុមហ៊ុនធ្វើការឈូសឆាយដាំដើមកៅស៊ូគ្រប់ចំនួនលើផ្ទៃដីដែលអាច ធ្វើអាជីវកម្មបានកាលពី ៣-៤ឆ្នាំមុន។ ព្រៃដែលមាននៅសេសសល់ក្នុងតំបន់នេះគឺជាព្រៃ (១) ព្រៃតំបន់ទ្រនាប (២) ព្រៃតំបន់ការពារសំរាប់ធ្វើការស្តារព្រៃឡើងវិញ។

**១៤០.** ការសិក្សាទៅលើរូបភាពនេត្រាទស្សន៍-១ អំពីស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់គំរោងអភិវឌ្ឍន៍ បង្ហាញថា ព្រៃឈើទាំងនេះមានលក្ខណៈជាព្រៃចំរុះ ស្ថានភាពគំរបព្រៃមានលក្ខណៈមធ្យម និងមានការរំខានពី ការកាប់រានធ្វើចំការរបស់ប្រជាជននៅរួចទៅហើយ ប៉ុន្តែត្រូវអន្តរក្រសួងរក្សាទុកសំរាប់ស្តារព្រៃឡើងវិញ។ ចំពោះរូបភាពនេត្រាទស្សន៍-២,៣ និង៤ សង្កេតឃើញ មានដីវាលដែលបានឈូសឆាយដោយក្រុមហ៊ុន ដើម្បីដាំ ដំណាំកៅស៊ូនៅក្នុងតំបន់នោះ។ តាមការជួបសន្ទនាជាមួយលោកអភិបាលស្រុក នឹងអាជ្ញាធរមូលដ្ឋានបាន អោយដឹងថា នៅក្នុងតំបន់ដូចបានរៀបរាប់ខាងដើមនេះពិតជាមានដីចំការស្វាយចន្ទី និងដីស្រែចំការចាស់

របស់ពួកគាត់មែនតែត្រូវបានក្រុមហ៊ុនដោះស្រាយឱ្យរួចហើយ តែនៅមានសេសសល់តិចតួចប៉ុណ្ណោះតាមមាត់អូរទឹកថ្លា ដែលជាភូមិទើបនឹងបង្កើតថ្មីតែក៏ក្រុមហ៊ុនមិនប៉ះពាល់ដែរគឺទុកឱ្យគាត់ប្រកបរចិញ្ចឹមជីវិត។

**១៤១.** តាមរយៈការសិក្សាអំពីស្ថានភាពប្រើប្រាស់នៅលើគន្លងហោះហើរចំងាយ ២៥គ.ម គ្របដណ្តប់លើផ្ទៃដីទំហំប្រមាណ ៨៦៥ហិកតា សង្កេតឃើញមានការប្រើប្រាស់ដី (ចំការបុស្ស) របស់ប្រជាជននៅក្នុងឃុំក្រយា។ ជាក់ស្តែងតាមការពិគ្រោះយោបល់ជាមួយមេឃុំក្រយា និងអភិបាលស្រុកសន្ទុក បានឱ្យដឹងថា នៅតំបន់នេះពិតជាមានដីស្រែ-ចំកាបុស្សរបស់អ្នកភូមិនៅទីនោះ ប្រមណជា ១០០ហិកតា ប្រហែល៤០គ្រួសារ។

## ៤-៤ លទ្ធផល និងការពិភាក្សា

### ៤-៤-១ រុក្ខអេកូឡូស៊ី

**១៤២.** បច្ចុប្បន្ននេះមិនទាន់មានការសិក្សាអំពីភាពសម្បូរណ៍បែប របស់រុក្ខជាតិបានច្បាស់លាស់នៅឡើយទេ។ តែទោះយ៉ាងនេះក្តី Dy Phon (2000) និងក្រសួងបរិស្ថាន (២០០២) បានបង្ហាញថា មានរុក្ខជាតិចំនួន ២.៣០៨ប្រភេទ ក្នុងចំណោមរុក្ខជាតិសរុបចំនួន ៨.០០០ប្រភេទ ដែលមាននៅក្នុងឥណ្ឌូចិន *(Flore Générale de L'Indochine)* ស្ថិតក្នុង **genera** ចំនួន ៨៥២ និង១៦៤អំបូរ។

**១៤៣.** ការសិក្សាបង្ហាញថា នៅក្នុងប្រភេទព្រៃស្រោងរបស់តំបន់សម្បទាន មានរុក្ខជាតិចំនួន ៦០ប្រភេទ (តារាង ៤-៦) ជុល្លិព្រឹក្ស៤៤ប្រភេទ (តារាង ៤-៧) និងតិណជាតិចំនួន ៥៥ប្រភេទ (តារាង ៤-៨) ខាងក្រោម។ ភាពសម្បូរណ៍បែប និងសមាសភាពនៃរុក្ខជាតិ ទាំងនោះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការពន្យល់បកស្រាយពីរចនាសម្ព័ន្ធទីជំរក លោក Scweithelm and Chhay 2007 បាននិយាយថា នៅក្នុងព្រៃល្បោះគ្របដណ្តប់ដោយប្រភេទរុក្ខជាតិ ដូចជា ខ្លុង ត្បែង ផ្ចិក រាំងភ្នំ នាងផ្អែក ក្នុងពេលដែលពពួកស្បូវ និងស្មៅព្រិច ជាពពួករុក្ខជាតិថ្នាក់ក្រោម។ ចំណែកឯនៅក្នុងព្រៃពាក់កណ្តាលស្រោងវិញ សម្បូរណ៍ទៅដោយ *Lagerstroemia cochinchinesis*, *Xylia xylocarpa*, *Cratoxylum conchinchinense*, and *Shorea siamensis*, *Irivingia malayana* and that understory *Arundinaria pusilla* and *Bambusa bambos*.

**១៤៤.** លោក Tran and Kol (1995) បានបញ្ជាក់ថា ក្នុងព្រៃស្រោង ប្រភេទឈើដែលលុបគឺ *Dipterocarpus alatus*, *Polyalthia cerasoides*, and *Mangifera duperrean*។ ប៉ុន្តែការសិក្សាបង្ហាញថា ប្រភេទឈើដែលលុបក្នុងតំបន់នេះគឺ *Lagerstroemia cochinchinesis*, *Polyalthia cerasoides*, *Amomum elephantrum*, and *Irvingia malayana*, and that understory species were *Korthalsia lacinosa* and *Nephelium hypoleucum*.

Draft

## តារាង៤-៦ ប្រភេទរុក្ខជាតិដែលមានដុះក្នុងព្រៃស្រោង

| ល.រ | ឈ្មោះក្នុងស្រុក | ការប្រើប្រាស់ | ចំណាត់ថ្នាក់ | ឈ្មោះវិទ្យាសាស្ត្រ |
|---|---|---|---|---|
| ១ | ពពូល | | 2 | Vitex sp.,Verbenacees |
| ២ | ពពេល | ពាណិជ្ជកម្ម | 2 | Hopea recopei, Dipterocarpacees |
| ៣ | កកោះ | ពាណិជ្ជកម្ម | 2 | Sindora cochinchinensis, Caesalpinees |
| ៤ | ក្រឡាញ់ | ពាណិជ្ជកម្ម | 2 | Dialium cochinchinensis, Caesalpinees |
| ៥ | ស្រឡៅ | ពាណិជ្ជកម្ម | 2 | Lagerstroemia sp, Lythracess |
| ៦ | ត្រសេក | ពាណិជ្ជកម្ម | 2 | Peltophorum ferrugineum, Caesalpinees |
| ៧ | សំព័រ | | 2 | Artocarpus sempervirens, Urticacees |
| ៨ | ផ្ដៀក | ពាណិជ្ជកម្ម | 3 | Anisoptera glabra, Dipterocarpacees |
| ៩ | ឈើទាល | ពាណិជ្ជកម្ម | 3 | Dipterocarpus costus, Dipterocarpacess |
| ១០ | ខ្វាវ | | 3 | Adina cordipolea, Rubiscees |
| ១១ | ច្រម៉ាស់ | សរសរផ្ទះ | 3 | Vatica astrotricha, Diptericaroacees |
| ១២ | ស្រគំ | សរសរផ្ទះ | 3 | Payena elliptica, Sapotacees |
| ១៣ | ត្រាច | ពាណិជ្ជកម្ម | 3 | Dipterocarpus intricatus, Dipterocarpacess |
| ១៤ | បង្គៅ | ថ្នាំត្រជាក់ | 4 | Aglaia gigantia, Meliacees |
| ១៥ | ល្ងៀង | ពាណិជ្ជកម្ម | 4 | Cratoxylon orumifolium, Hypericacees |
| ១៦ | ធ្លក | ពាណិជ្ជកម្ម | 4 | Parimarium annamensis, Rosacees |
| ១៧ | ព្រីង | អុសដុត សរសរផ្ទះ | 4 | Eugenia sp, Myrtacees |
| ១៨ | ព្រុស | បង្គោលរបង | 4 | Garcinia ferrea |
| ១៩ | ក្រាយ | ធ្យូង | 4 | Albizzia thorelli, Mimosees |
| ២០ | ត្រមែង | ដុតធ្យូង | 4 | Carallia lucida, Rlhzophoracees |
| ២១ | ទ្រមូង | ធ្វើម្ហូរ | 4 | Garcinia schomburghiana-Guttiferes |
| ២២ | ស្នាច់ | ពាណិជ្ជកម្ម | 4 | Melaleuca leucadendron, Myrtacees |
| ២៣ | ស្មាក្របី | | 4 | Knema Corticosa |
| ២៤ | ស្វាយព្រៃ | ពាណិជ្ជកម្ម | 4 | Mangfifera, indeca, Anacardiacess |
| ២៥ | ពភ្លាប្រើស | | 5 | Grewia paniculata |
| ២៦ | ពង្រ | ហូបផ្លែ | 5 | |
| ២៧ | ដើមពួច | | 5 | |

| | | | | |
|---|---|---|---|---|
| ២៨ | ចំបក់ | ពាណិជ្ជកម្ម | 5 | |
| ២៩ | ដង្កាបក្តាម | ហូបផ្លែ | 5 | Antidesma ghaasembillia. |
| ៣០ | ដក់ព័រ | | 5 | Markhamia pierrei. |
| ៣១ | ដើមប៉ា | | 5 | |
| ៣២ | ដើមឡង់ | | 5 | |
| ៣៣ | ភ្លៅសំពោច | ធ្វើអុស | 5 | |
| ៣៤ | ភ្នៀវ | ហូបផ្លែ | 5 | |
| ៣៥ | ឈើភ្លើង | ថ្នាំសសៃរ | 5 | Diospyros nitida |
| ៣៦ | ស្មៀង | | 5 | |
| ៣៧ | សិរមាន់ | ហូបផ្លែ | 5 | Neptcelium xerospermum |
| ៣៨ | អាឡោក | | 5 | |
| ៣៩ | អំពិលព្រៃ | | 5 | |
| ៤០ | ញរព្រៃ | | 5 | Morinda |
| ៤១ | គុម្ពភ្លេង | | 5 | |
| ៤២ | ម្កាក់ព្រៃ | | 5 | |
| ៤៣ | រម៉ាំង | | 5 | |
| ៤៤ | ភ្លូ | | 5 | |
| ៤៥ | ភ្លូង | បង្គោលរបង | 5 | Memecylon Laevigatum |
| ៤៦ | រកា | | 5 | Bombax ceiba Bombaceae |
| ៤៧ | គ្រង់ | ហូបផ្លែ | 5 | Aporosa sp. |
| ៤៨ | ក្រឡាបូស | | 5 | |
| ៤៩ | ក្រូចព្រៃ | | 5 | |
| ៥០ | រំដួល | ហូបផ្លែ | 5 | Popowia diospyrifolia |
| ៥១ | រំដេញ | | 5 | |
| ៥២ | ត្របែកព្រៃ | | 5 | |
| ៥៣ | ព្រហូត | ថ្នាំរាគមួល | 5 | |
| ៥៤ | ស្ពង់ | | 5 | Tetrameles mudiflora, Datiscacees |
| ៥៥ | សង្កែ | | 5 | |
| ៥៦ | សំបោរបាយ | | 5 | |

Draft

| | | | | |
|---|---|---|---|---|
| ៥៧ | ភ្លៅសំពោច | ចំណីរសត្វហូបផ្លែ | 5 | |
| ៥៨ | ស្នួល | | 5 | Dalbergia reigresens |
| ៥៩ | ស្នាយព្រៃ | | 5 | Streblus asper |
| ៦០ | ទំពូង | ថ្នាំសសៃរ | 5 | Mallotus Coehinchinensis |

**តារាង៤-៧ ប្រភេទរុក្ខព្រឹកដែលជួបប្រទះតាមសងខាង Transect ចំងាយ ១០ម៉ែត្រ**

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | សរុប | ការប្រើប្រាស់ |
|---|---|---|---|---|
| ១ | ឫស្សី | | ច្រើន | |
| ២ | ជើងចាប | | ច្រើន | |
| ៣ | វល្លិល្មៀត | | ច្រើន | |
| ៤ | ឥសីផ្សំស្រេច | | ជួបញឹកញាប់ | |
| ៥ | ដើមទ្រៀល | | ជួបញឹកញាប់ | |
| ៦ | អន្លង់ព្រៃ | | ជួបញឹកញាប់ | |
| ៧ | ដើមពូច | | ជួបញឹកញាប់ | |
| ៨ | ពាន់ធ្លង | | ច្រើន | |
| ៩ | រំពាត់ជ្រូក | | ច្រើន | |
| ១០ | ចាក់សែង | | ច្រើន | |
| ១១ | ជំឡូងទឹក | | ច្រើន | យកមើមហូប |
| ១២ | ពោះមាន់ | | ច្រើន | ចងរបង វិញពូរ |
| ១៣ | ធ្មេញត្រី | | ច្រើន | |
| ១៤ | ស្លែង | | ច្រើន | |
| ១៥ | ផ្ដៅកន្ទុង | | ជួបញឹកញាប់ | វិញពូរ |
| ១៦ | ផ្ដៅឆ្នាំង | | ជួបញឹកញាប់ | វិញពូរ ចាកសង្រែក |
| ១៧ | ខ្ចូត | | ច្រើន | |
| ១៨ | អំពិល | | ច្រើន | កាប់ដើមយកទឹកផឹក |
| ១៩ | ជង្គង់អណ្ដើក | | ច្រើន | ហូបផ្លែ |
| ២០ | ជន្ទល់ពងមាន់ | | ជួបញឹកញាប់ | |
| ២១ | ដើមអញ្ចាញ | | ច្រើន | ថ្នាំគ្រជាក់ |
| ២២ | ម្ទូរល្មម | | ច្រើន | ធ្វើម្ហូប |
| ២៣ | ភ្លូស្បាត | | ច្រើន | ថ្នាំផ្សះ |

Draft

| | | | | |
|---|---|---|---|---|
| ២៤ | បាយញ៉ៀញ | | ច្រើន | |
| ២៥ | វល្លិស្លែងពណិ | | ច្រើន | ចាក់ធ្វើកន្ទេល |
| ២៦ | វល្លិកញ្ចូញ | | ជួបញឹកញាប់ | ក្រងទ្រូ ស្នេហ៍មុខ |
| ២៧ | វល្លិក្តិនទា | | ជួបញឹកញាប់ | ថ្នាំគ្រុនចាញ់ |
| ២៨ | ពាន់ដែក | | ជួបញឹកញាប់ | |
| ២៩ | ជន្ទល់មេឃ | | ច្រើន | |
| ៣០ | ដំឡូងទាន | | ច្រើន | យកមើមហូប |
| ៣១ | ដោះក្របី | | ច្រើន | |
| ៣២ | កញ្ចាស់ | | ច្រើន | |
| ៣៣ | ល្អាក់ទឹក | | ច្រើន | |
| ៣៤ | ទ្រមូងខ្មោះ | | ច្រើន | ក្របលប ទ្រូ ព្រួល |
| ៣៥ | ខ្លាយមាន់ | | ជួបញឹកញាប់ | |
| ៣៦ | ទាលក្រាញ់ | | ជួបញឹកញាប់ | ថ្នាំសត្វ |
| ៣៧ | បាយក្តាំង | | ជួបញឹកញាប់ | |
| ៣៨ | ក្របាស់ព្រៃ | | ជួបញឹកញាប់ | ថ្នាំស្បូន |
| ៣៩ | កន្ទេចអាល | | ច្រើន | |
| ៤០ | រំពាត់សេះ | | ច្រើន | |
| ៤១ | ជើងគោស្បាត | | ច្រើន | ថ្នាំស្បូន |
| ៤២ | ត្រដិត | | ជួបញឹកញាប់ | |
| ៤៣ | អង្ក្រែដែក | | ច្រើន | ថ្នាំកូនខ្ចី ជំនួយកំលាំង |
| ៤៤ | ត្បាល់ដែក | | ច្រើន | ថ្នាំប៉ូវក្រលាន |

## តារាង៤-៨ ប្រភេទ ទិណជាតិដែលបានជួបប្រទះតាមសងខាងផ្លូវ១០

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | សរុប | ការប្រើប្រាស់ |
|---|---|---|---|---|
| ១ | ដើមផ្កាវ | | ច្រើន | |
| ២ | ប្រទាល | | ច្រើន | |
| ៣ | បណ្តូលពេជ្រ | | ច្រើន | |
| ៤ | ជុជ | | ច្រើន | |
| ៥ | ជុយ | | ច្រើន | |
| ៦ | ជីស | | ច្រើន | |
| ៧ | ពោះវៀនមាន់ | | ច្រើន | |



Draft

| | | | | |
|---|---|---|---|---|
| ៨ | ដោះគង់ | | ច្រើន | |
| ៩ | ផោម | | ច្រើន | |
| ១០ | ត្រៀល | | ច្រើន | |
| ១១ | សៅម៉ៅ | | ជួបញឹកញាប់ | |
| ១២ | ខ្លែងពណិ | | ច្រើន | |
| ១៣ | អន្ទុង | | ច្រើន | |
| ១៤ | កណ្ដាប់ចង្អេរ | | ច្រើន | |
| ១៥ | គុយ | | ច្រើន | |
| ១៦ | ក្របីគ្រោស | | ច្រើន | |
| ១៧ | ក្រវ៉ាន់ | | ច្រើន | |
| ១៨ | ត្រឡាំពេន | | ច្រើន | |
| ១៩ | តាលេនពេន | | ច្រើន | |
| ២០ | ទន្ទិញក្រហម | | ច្រើន | |
| ២១ | ទន្ទិញស | | ច្រើន | |
| ២២ | ទឹកដោះ | | ច្រើន | |
| ២៣ | យាវ | | ច្រើន | |
| ២៤ | ពន្លៃព្រៃ | | ច្រើន | |
| ២៥ | ស្មៅបាយក្ដាំង | | ច្រើន | ចំណីសត្វ |
| ២៦ | ស្មៅម្ដេងព្រៃ | | ច្រើន | ហូប |
| ២៧ | ស្មៅស្លែថ្ម | | ច្រើន | |
| ២៨ | ស្មៅកន្ទុយភេ | | ជួបញឹកញាប់ | |
| ២៩ | ស្មៅអន្ទៀន | | ច្រើន | ចំណីសត្វ |
| ៣០ | ស្មៅត្រសិត | | ច្រើន | |
| ៣១ | ស្មៅស្បូវបាយ | | ច្រើន | ប្រក់ផ្ទះ |
| ៣២ | ស្មៅស្បូវអណ្ដាស | | ច្រើន | |
| ៣៣ | ស្មៅស្បូវកន្ទួង | | ច្រើន | ប្រក់ផ្ទះ |
| ៣៤ | ស្មៅស្បូវឃ្លាំង | | ច្រើន | ប្រក់ដំបូលផ្ទះ |
| ៣៥ | ស្លែដី | | ច្រើន | |
| ៣៦ | ថ្នក់ទឹក | | ច្រើន | |
| ៣៧ | កណ្ដាលបាត | | ច្រើន | |
| ៣៨ | ផ្សិតដំបូក | | ច្រើន | |

Draft

| | | | | |
|---|---|---|---|---|
| ៣៩ | ផ្កាអកគីដេ | | ជួបញឹកញាប់ | |
| ៤០ | ផ្សិតចំបក់ | | ច្រើន | ចំណីសត្វ |
| ៤១ | ផ្សិតដី | | ច្រើន | |
| ៤២ | ផ្សិតភ្លើង | | ច្រើន | យកហូប |
| ៤៣ | ផ្សិតឈើ | | ច្រើន | |
| ៤៤ | ផ្សិតកញ្ជេរ | | ច្រើន | |
| ៤៥ | ផ្សិតផ្ទុកផ្គរ | | ច្រើន | ចំណីសត្វ |
| ៤៦ | ផ្សិតត្រចៀកកណ្តុរ | | ច្រើន | យកហូប |
| ៤៧ | ប្រទាលជាន់ព្រៃ | | ជួបញឹកញាប់ | |
| ៤៨ | ត្បាល់ដែក | | ជួបញឹកញាប់ | |
| ៤៩ | ផ្តៅល្វីង | | ច្រើន | វិញពួរ ឬ ខ្សែ |
| ៥០ | ផ្តៅកន្ទុះ | | ច្រើន | វិញពួរ ឬ ខ្សែ |
| ៥១ | ផ្តៅឆាំង | | ជួបញឹកញាប់ | វិញពួរ ឬ ខ្សែ |
| ៥២ | ផ្តៅសន្ទូច | | ជួបញឹកញាប់ | |
| ៥៣ | ចង្កេះអង្រ្កង | | ជួបញឹកញាប់ | ជំងឺទាសរីងរៃ |
| ៥៥ | ដើមក្រេះ | | ច្រើន | បន្ទាបពុលអាហារ |

**១៤៥.** *យោងតាមផែនទីប្រើប្រាស់ដី និងគំរបព្រៃឈើឆ្នាំ២០០៦ របស់រដ្ឋបាលព្រៃឈើបានបង្ហាញថា មានសារព័ន្ធរុក្ខជាតិចំនួនពីរប្រភេទគឺ : (១) ព្រៃស្រោងមានចំនួន ៧.៩៥៥ ហិកតា ស្មើនឹង ៩៥.៩១% (២) ដីព្រៃផ្សេងៗមានចំនួន ៣៨ ហិកតា ស្មើនឹង ០.៤៧% និងដីគ្មានគំរបព្រៃមានចំនួន ១០៧ហិកតា ស្មើនឹង៣.២០% ។ ដើម្បីធ្វើការសិក្សាទៅលើសារព័ន្ធរុក្ខជាតិដែលមាន នៅក្នុងតំបន់គំរោងវិនិយោគដំណាំកៅស៊ូ របស់ក្រុមហ៊ុន TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC Co., Ltd. ក្រុមការងារ GCF បានជ្រើសរើសគំរូសំណាកចំនួន ១២ឡូតិ៍ ក្នុងនោះមាន ឡូតិ៍គំរូចំនួន៦ ស្ថិតនៅចំកន្លែងដាំកៅស៊ូ ដែលក្រុមហ៊ុនបានដាំតាំងពីឆ្នាំ ២០០៧, ២០០៨, និង២០០៩ មកម្លេះ ។ ចំណែក ឡូតិ៍គំរូចំនួន ០៦ទៀត នៅក្នុងតំបន់ទ្រនាប់ និងតំបន់បំរុងទុកស្តារព្រៃឡើងវិញ (ឧបសម្ព័ន្ធ១-២ និងរូបភាព Eye view-1, Photo-Index K ,L ,M ,O ,P* (ឧបសម្ព័ន្ធ៤-៦)) ។

## ៤-៤-២ សត្វអេកូឡូស៊ី

**១៤៦.** *នៅក្នុងវិធីសាស្ត្រនៃការសិក្សាសត្វព្រៃដែលអាចមានវត្តមានក្នុងទីតាំងគំរោងស្នើសុំ ក្រុមការងារបានប្រើប្រាស់វិធីសាស្ត្រពីរយ៉ាងគឺ : (១) តាមរយៈការអង្កេតតាមឡូតិ៍គំរូនិមួយៗ ចាប់ពីថ្ងៃទី ២១ ខែឧសភា*

Draft

*និងថ្ងៃទី ១៨-២០ ខែ កក្កដា ឆ្នាំ២០១១ ដើម្បីអង្កេតទៅលើដានជើងសត្វ លាមក សំរែក ស្នាម ការជួបប្រទះ និង (២)តាមរយៈ ការសំភាសន៍ជាមួយប្រជាពលរដ្ឋ ដោយប្រើប្រាស់សៀវភៅផនិកសត្វប្រទេសកម្ពុជា និងសៀវភៅសត្វស្លាប ប្រទេសកម្ពុជាជាជំនួយ ។ នៅក្នុងលទ្ធផលនៃការសិក្សា ក្រុមការងារបានកត់ត្រានូវពពួកសកុណជាតិចំនួន ៣២ ប្រភេទ (តារាង៤-៩ ប្រភេទសកុណជាតិដែលមាន នៅក្នុងតំបន់គំរោងអភិវឌ្ឍន៍) ។ ក្នុងចំណោមសកុណជាតិ ទាំងអស់នេះ* Chestnut-headed Partridge *(Arborophilia cambodiana)* *ត្រូវបានចាត់ទុកថាជាប្រភេទ ដែលកម្រនៅក្នុងប្រទេសយើង ។*

**តារាង ៤-៩ : ចំនួនសត្វព្រៃ (សត្វស្លាប) ដែលបានអង្កេតនៅក្នុងតំបន់របស់ក្រុមហ៊ុន**

| No | Khmer name | English name | Scientific name | # of records |
|---|---|---|---|---|
| ១ | ទាវខៀវ | Indian Roller | *Coracias benghalensis* | 6 |
| ២ | ត្រដេវតូច | Green Bee-eater | *Merops orientalis* | 5 |
| ៣ | សេកក្រិច | Vernal Hanging Parrot | *Loriculus vernalis* | 10 |
| ៤ | សេកអាត់ | Blossom-headed Parakeet | *Psittacula roseata* | 24 |
| ៥ | ពញ្ញាក់ | Indian Nightjar | *Caprimulgus asiaticus* | 1 |
| ៦ | មាម | Glavcidium Brodiei | - | 3 |
| ៧ | ត្រដេវរិចទូល | Red-wattled Lapwing | *Vanellus indicus* | 2 |
| ៨ | កុកក្រក | Chinese Pond Heron | *Ardeola bacchus* | 1 |
| ៩ | អន្ទេបខ្មៅ | Black Drongo | *Dicrurus macrocercus* | 2 |
| ១០ | អន្ទេបកន្ទុយកន្ត្រៃ | Greater Racket-tailed Drongo | *Dicrurus paradiseus* | 1 |
| ១១ | ល្វាចេក | Oriental Magpie Robin | *Copsychus saularis* | 1 |
| ១២ | កញ្ច្រៀច | Vinous-breasted Starling | *Sturnus burmannicus* | 2 |
| ១៣ | ពពិចក្បាលខ្មៅចុងខ្នងស | Sooty-headed Bulbul | *Pycnonotus aurigaster* | 15 |
| ១៤ | មាន់ព្រៃ | Red Junglefowl | *Gallus gallus* | 2 |
| ១៥ | ក្រួចអ៊ីត | Barred Buttonquail | *Turnix suscitator* | 5 |
| ១៦ | ត្រសេះតូច | Common Flameback | *Dinopium javanense* | 2 |
| ១៧ | បាគូ | Common Hoopoe | *Upupa epops* | 3 |
| ១៨ | ជចាត | Common Kingfisher | *Alcedo atthis* | 2 |
| ១៩ | ខ្លែងខ្មៅ | Black Kite | *Milvus migrant* | 1 |
| ២០ | ញាំង | Wreathed Hornbill | *Aceros undulates* | 1 |
| ២១ | សារិកាកែវក្របី | White-vented Myna | *Acridotheres javanicus* | 2 |
| ២២ | គ្រលីងគ្រលង | Black-collared Straling | *Sturnus nigricollis* | 1 |

| | | | | |
|---|---|---|---|---|
| ២៣ | ចាបក្រច | Yellow-vented Bulbul | *Pycnonotus goiavier* | 1 |
| ២៤ | ក្រួចសំពៅ | Chestnut-headed Partridge | *Arborophilia cambodiana* | 3 |
| ២៥ | ចេកខ្ចីស្លាបខៀវ | Blue-winged Leafbird | *Chloropsis cochinchinensis* | 2 |
| ២៦ | ចែកខ្ចី | Golden-fronted Leafbird | *Chloropsis aurifrons* | 1 |
| ២៧ | ចេកទេសតូច | Small Minivet | *Pericrocotus cinnamomeus* | 4 |
| ២៨ | លលកបាយ | Spotted Dove | *Streptopelia chinensis* | 2 |
| ២៩ | ចេកទុំខៀវ | Asian Brown Flycatcher | *Muscicapa dauurica* | 3 |
| ៣០ | ចាបដង្កូវ | Prinia | *Prinia spp* | 21 |
| ៣១ | ជាបតេត | Common Tailorbird | *Orthotomus sutorius* | 3 |
| ៣២ | តូត | Burceros Bicornis | - | 5 |
| *Number of species* | | | 32 | |
| *Number of individuals* | | | | 136 |

**១៤៧.** ការសិក្សាបង្ហាញថា បក្សីដែលសម្បូរណ៍ជាងគេនៅក្នុងតំបន់សម្បទាននេះគឺ Sooty-headed Bulbul *(Pycnonotus aurigaster)*, Spotted Dove *(Streptopelia chinensis)*, Prinia *(Prinia spp)*, and Indian Roller *(Coracias benghalensis)* ដូចការអះអាងរបស់លោក *Joe and Other 2001* ដែលថា បក្សីទាំងនេះមានចំនួនច្រើនលើសលុបនៅតំបន់ខាងត្បូងប្រជ្រាយឥណ្ឌូចិន។

**១៤៨.** លោក Tan and Poole, 2003 បានបញ្ជាក់ថា Blossom-headed Parakeet *(Psittacula roseata)* and Red Junglefowl *(Gallus gallus)* ដូចទៅនឹងរបាយការណ៍របស់រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សអន្តរជាតិនៅឆ្នាំ ២០០៧ ថាប្រភេទបក្សីទាំងអស់នេះជាប្រភេទលប់នៅក្នុងប្រទេសកម្ពុជា ហើយភាគច្រើនជាប្រភេទដែលរស់នៅលើចុងឈើ (Barney et al, 2000)។

**១៤៩.** បក្សីភាគច្រើនដែលជួបប្រទះនៅក្នុងតំបន់សម្បទានគឺ បក្សីដែលរស់លើចុងឈើ និងស៊ីចំណីលើដី។ ដោយឡែកបក្សីទឹក Common Kingfisher *(Alcedo atthis)*, Chinese Pond Heron *(Ardeola bacchus)* និង Black-capped Kingfisher *(Halcyon pileata)* ក៏មានច្រើនដែរ ដោយសារតែមជ្ឈដ្ឋានរស់នៅមានអំណោយផល។ តែចំពោះ Prinia, Chinese Francolin, Partridge, and Junglefowl ជាប្រភេទដែលរស់នៅ Understory ដូច្នេះហើយទើបសង្កេតឃើញថា បក្សីទាំងនេះមានលក្ខណៈប្លែកគ្នាខ្លាំងទៅតាមលក្ខណៈនៃមជ្ឈដ្ឋាននិមួយៗ (Masphal et al, 2009)។

**១៥០.** ការសិក្សាបង្ហាញថា មានថនិកសត្វចំនួន ០៥ប្រភេទ (តារាង៤-១០ ប្រភេទថនិកសត្វដែលជួបប្រទះនៅក្នុងតំបន់សម្បទាន។ ក្នុងចំណោមសត្វទាំងអស់នេះ គ្មានប្រភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់ (សេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០០៧) ទេ។ ដោយឡែក Wild pig *(Sus*

Draft

*scrofa)* Red muntjac *(untiacus muntjak)* ត្រូវបានចាត់ទុកថាជាប្រភេទដែលសម្បូរណ៍ នៅក្នុងប្រទេសយើង។

**តារាង៤ -១០: ចំនួនសត្វព្រៃ (ថនិកសត្វ) ដែលបានអង្កេតនៅក្នុងតំបន់របស់ក្រុមហ៊ុន**

| ល.រ | ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | រាប់តាមលំដាប់នៃ | | | | សរុប |
|---|---|---|---|---|---|---|---|
| | | | ការមើលឃើញ | ដានជើង | សំរែក | លាមក | |
| ១ | ក្តាន់ញ្ជែង | Tragulus Napu | ៦ | ៤ | ១ | ០ | ១១ |
| ២ | ឈ្លូស | Muntiacus Muntjak | | ៩ | ០ | ០ | ៩ |
| ៣ | ជ្រូកព្រៃ | Suss Scrota | | ១៩ | ០ | ២ | ២១ |
| ៤ | ស្កាចធំ | Herpestes Urva | ១ | ០ | ០ | ០ | ១ |
| ៥ | សំពោចធំ | Vivrra Megaspila | ៦ | ០ | ០ | ០ | ៦ |
| សរុបរួម | | | ១៣ | ៣២ | ១ | ២ | ៤៨ |

**១៥១.** តារាង៤-១១ ខាងក្រោមបានបង្ហាញឱ្យឃើញថា ភាពសំបូរបែបនៃសត្វស្លាបដែលបានកត់ត្រានៅក្នុងតំបន់សិក្សាស្រាវជ្រាវ គឺមានចំនួនស្មើនឹង ៦៤ភាគរយ នៃលទ្ធផលដែលទទួលបានពីការសំភាសន៍ជាមួយប្រជាជនមូលដ្ឋានរស់នៅក្បែរតំបន់ស្រាវជ្រាវ និងត្រូវជា ៥ភាគរយ នៃចំនួនសត្វស្លាបសរុបក្នុងប្រទេសកម្ពុជា។

**១៥២.** មានថនិកសត្វចំនួន ០៥ប្រភេទត្រូវបានកត់ត្រា (**ក្នុងតារាង៤-១០ ចំនួនសត្វព្រៃ (ថនិកសត្វ) ដែលបានអង្កេតនៅក្នុងតំបន់របស់ក្រុមហ៊ុន**)។ ក្នុងចំណោមពពួកថនិកសត្វទាំងអស់នេះមានឈ្លូស និងជ្រូកព្រៃ ត្រូវបានចាត់ថាជាប្រភេទមានដោយបង្គួរ (MAFF,2007)។ តារាងលេខដដែលនេះ ក៏បានបង្ហាញអោយឃើញផងដែរថា ថនិកសត្វដែលកត់ត្រាបានមានចំនួនប្រមាណ៣៣.៣៤ភាគរយ នៃចំនួនសត្វដែលបានពីការសំភាសន៍ប្រជាជនមូលដ្ឋាន ហើយត្រូវជា២.៩៥ភាគរយ នៃចំនួនថនិកសត្វសរុបនៅក្នុងប្រទេសកម្ពុជា។

**តារាង៤-១១: ការប្រៀបធៀបពីភាពសំបូរបែបរបស់សត្វស្លាប និងថនិកសត្វនៅក្នុងតំបន់សិក្សាស្រាវជ្រាវ ទៅនឹងលទ្ធផលពីការសំភាសន៍តំបន់ព្រៃការពារសេនេទិកស្រែពក និងទូទាំងប្រទេស**

| ប្រភេទ | តំបន់សិក្សាស្រាវជ្រាវ | ពីការសំភាសន៍ | ទូទាំងប្រទេស |
|---|---|---|---|
| សត្វស្លាប | ៣២ | ៥០ | ៦៣០ |
| ថនិកសត្វ | ០៥ | ១៥ | ២១៨ |

*ប្រភព : ការអង្កេត និង សំភាសន៍*

## ៤-៤-៣ អំពីមច្ឆាជាតិ

**១៩៣.** នៅក្នុងតំបន់ដីសម្បទានក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** សំបូរប្រភពទឹកស្រទាប់លើមធ្យម នៅក្នុងទីតាំងសម្បទានរបស់ក្រុមហ៊ុន យើងសង្កេតឃើញមានប្រព័ន្ធអូរជាច្រើន តែប្រព័ន្ធផ្លូវទឹកទាំងនេះភាគ ច្រើនរីងគោកនៅរដូវប្រាំងពោលគឺមានតែ **អូរធំ និង អូរព្រៀល** ដែលហូរកាត់ចំណុចកណ្តាលទីតាំងដីសម្បទានរបស់ក្រុមហ៊ុន ដែលអូរទាំងនេះមានទឹកដក់គ្រប់រដូវ (ហូរចាក់ចូលទៅអូរ) ជាប្រចាំ និងជា ប្រភពទឹកប្រើប្រាស់ ដ៏សំខាន់របស់ប្រជាជននៅតំបន់នោះទាំងមូល ហើយក៏ជាជំរកត្រីផងដែរ។ អូរទាំងពីរជាប្រភពទឹកមួយយ៉ាងសំខាន់ផងដែរសំរាប់ក្រុមហ៊ុន ក្នុងការប្រើប្រាស់សំរាប់ដាំដើមឈើរបស់ក្រុមហ៊ុនតែម្តងព្រោះ អូរនេះហូរកាត់ទីតាំងការដ្ឋានរបស់ក្រុមហ៊ុនផ្ទាល់។ តាមការសាកសួរ ពីប្រជាពលរដ្ឋផ្ទាល់នៅក្នុងតំបន់បញ្ជាក់ថា កាលពីដើមរាងមកអូរទាំងនេះជាសំបុក ត្រីយ៉ាងសំបូរបែប (សម័យពុកម៉ែគាត់) រហូតដល់កំឡុងឆ្នាំ២០០០ រហូតដល់ ឆ្នាំ២០០៨ ពួកគាត់ក៏ធ្លាប់នេសាទ បាននូវប្រភេទត្រីសំខាន់ៗទាំងអស់នោះដែរ (ទាំងប្រភេទត្រីស និងត្រីខ្មៅ) ដូចមានក្នុងតារាងខាងក្រោម:

**តារាង-១: ប្រភេទត្រីកំណត់ទៅតាមជំរកនៅរដូវប្រាំង**

| ក្រុម | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះ FAO | ឈ្មោះខ្មែរ | ជំរកនៅរដូវប្រាំង |
|---|---|---|---|---|
| ត្រីខ្មៅ ឬត្រីបឹង | | | | |
| 1 | *Trichogaster trichopterus* | Threespot gourami | ត្រីកំភ្លាញសំរែ |  |
| 2 | *Clarias macrocephalus* | Blackskin catfish | ត្រីអណ្តែងទន់ |  |
| 3 | *Clarias nieuhofi* | | ត្រីអណ្តែងងាំង |  |
| 4 | *Macrognathus taeniagaster* | | ត្រីខ្ជឹង |  |
| 5 | *Macrognathus sp.* | Shortspine eel | ត្រីឆ្លូញ |  |
| 6 | *Oxyelotris marmorata* | Marbled sleeper | ត្រីដំរី |  |
| 7 | *Rasbora borapetensis* | Blackline rasbora | ត្រីចង្វាស្រលូង | |

Draft

| | | | | |
|---|---|---|---|---|
| | | | |  |
| 8 | *Henicorhynchus cryptopogon* | | ត្រីរៀលអង្កាម |  |
| 9 | *Channa striata* | Chevron snakehead | ត្រីរ៉ស់ |  |

## តារាង-១ (ត)

| ក្រុម | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះ FAO | ឈ្មោះខ្មែរ | ជំរកនៅរដូវប្រាំង |
|---|---|---|---|---|
| | | ត្រីស ឬត្រីបឹង | | |
| 10 | *Cylocheilichthys apogon* | Beardless barb | ត្រីស្រកាក្ដាម |  |
| 11 | *Glossogobius aureus* | Golden tank goby | ត្រីខ្សាន្ត |  |
| 12 | *Channa micropeltes* | Giant snakehead | ត្រីឆ្តោ |  |
| 13 | *Anabas testudineus* | Climbing perch | ត្រីក្រាញ់ |  |
| 14 | *Mystus singaringan* | | ត្រីកញ្ចុះ |  |
| 15 | *Mystus multiradiatus* | | ត្រីកញ្ចុះឆ្នូត |  |
| 16 | *Mystus mysticetus* | | ត្រីកញ្ចុះឆ្នូត |  |
| 17 | *Xenentodon canciloides* | | ត្រីផ្ទោង | |

Draft

| | | | | |
|---|---|---|---|---|
| | | | |  |
| 18 | *Dermogenyspusilla* | | ត្រីផ្ទោង |  |
| 19 | *Chitala lopis* | Giant featherback | ត្រីស្លាត |  |
| 20 | *Puntioplites falcifer* | | ត្រី ច្រកែង |  |
| 21 | *Ompok sp.* | | ត្រីគាអោន |  |
| 22 | *Leiocassis stenomus* | | ត្រីឆ្លាំង |  |
| 23 | *Hampala macrolepidota* | | ត្រីខ្មាន់ |  |
| 24 | *Luciosoma setigerum* | Apollo sharkminnow | ត្រីចង្វារនទោង |  |

Draft

១៥៤. ពួកគាត់បានបញ្ជាក់ថា ធនធានត្រីនៅតំបន់នេះ ត្រូវបានធ្លាក់ចុះទៅៗ រហូតស្ទើរតែរកមិនបានហូបទៀតផង។ ជាក់ស្តែងក្នុងការចុះទៅជាមួយនឹងអ្នកនេសាទក្រុមការងារយើងបានធ្វើការស្រង់យកប្រភេទត្រីដែលពួកគាត់ធ្វើការនេសាទបានដូចមានរូបភាពខាងក្រោម:





ប្រភេទត្រីដែលរកបាននៅក្នុងស្ទឹងជិនិត ដោយប្រើឧបករណ៍មង



ប្រភេទត្រីដែលរកបាននៅក្នុងស្ទឹងជិនិត ដោយប្រើឧបករណ៍មង និងលប



ប្រភេទត្រីដែលរកបាននៅក្នុងស្ទឹងជិនិត ដោយប្រើឧបករណ៍មង លប់ និង សំណាញ់



ប្រភេទឧបករណ៍ដែលប្រើប្រាស់សំរាប់នេសាទ

Draft

**១៩៥. ផលនេសាទនិងចំណូលអំពីផលនេសាទ:** ការសិក្សាបានបង្ហាញថា ប្រភពចំណូលសំខាន់របស់ពួកគាត់ គឺមិនបានមកពីផលនិងអនុផលនេសាទទេ។ តាមទិន្នន័យពីការធ្វើបទសំភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋនៅក្នុងតំបន់ទាំងនោះប្រមាណជា ៣០គ្រួសារ បានបង្ហាញឱ្យឃើញថា ភាគច្រើនពួកគាត់ធ្វើការនេសាទតែនៅរដូវវស្សា តែប៉ុណ្ណោះ ហើយទិន្នផលនៃការនេសាទបានតិចឬច្រើន អាស្រ័យទៅលើធនធានត្រីដែលមាននៅក្នុងទឹក (តាមហេងស៊យ)។ តាមការអង្កេត និងសាកសួរពីអ្នកនេសាទនៅតំបន់ទីតាំងស្នើសុំនោះបានឱ្យដឹងថា ទិន្នផលនៃការនេសាទមានការថយចុះខ្លាំងណាស់ បើប្រៀបធៀបទៅនឹងការនេសាទពីឆ្នាំ២០០០-២០០៥ រហូតដល់ឆ្នាំ២០០៧។ ចំពោះប្រភេទត្រីដែលរកបាន ពីការនេសាទគឺអាស្រ័យទៅលើឧបករណ៍របស់ពួកគាត់ មានដូចជា: (១) មងដែលពួកគាត់ នេសាទបានប្រភេទត្រីរ៉ស់ ត្រីផ្ទក់ ត្រីឆ្លាំង ត្រីរៀល ត្រីស្លាត ដែលពួកគាត់អាចនេសាទបានពី ១-៣គីឡូក្រាម ក្នុង១ថ្ងៃ ហើយថ្ងៃខ្លះអាចបានច្រើនជាងនេះ ប្រភេទត្រីខាងលើអាចលក់បានតំលៃ ៤០០០-១០០០០រៀល ក្នុងមួយគីឡូក្រាម (២) ឧបករណ៍មុងអួស ពួកគាត់នេសាទបានប្រភេទត្រីតូចៗ ដូចជាកំពឹសក្តាម ខ្យង កញ្ចុះ.....។ល។ (៣) ប្រភេទឧបករណ៍ឆក់ គឺមានប្រើប្រាស់ចំពោះជនចំណូលពីខាងក្រៅភូមិដែលពួកគាត់ មិនស្គាល់អត្តសញ្ញាណថាមកពីភូមិណានោះទេ តែពេលខ្លះពួកគាត់ពួកគាត់ស្គាល់ ថាជាអ្នកធ្វើការឱ្យក្រុមហ៊ុន ដីសម្បទានផងដែរ។ ពួកគាត់បានបន្ថែមទៀតថា នៅទីនេះបច្ចុប្បន្ន មិនត្រឹមតែប្រើឧបករណ៍ឆក់ទេ ជូនកាល មានរហូតដល់បោះថ្នាំពុលចូលទៅអន្លងត្រីទៀតផង ដែលនេសាទបានត្រីគ្រប់ប្រភេទទាំងតូចទាំងធំ (៥) ឧបករណ៍រណោង ឬសន្ទូច ហើយប្រភេទត្រីដែលនេសាទបានមានដូចជា ត្រីអណ្តែង ត្រីផ្ទក់ឬត្រីរ៉ស់ ត្រីឆ្លាំង ត្រីស្លាត ត្រីឆ្តោ .......។ល។

**១៩៦.** តាមរបាយការណ៍ដែលក្រុមការងារបានសំភាសន៍ជាមួយអ្នកនេសាទ បានបង្ហាញថា ជាទូទៅត្រី ដែលជាភោគផលធម្មជាតិនៅក្នុងតំបន់នេះមានច្រើនប្រភេទដូចជា: ត្រីកំភ្លាញសំរ៉ែ ត្រីអណ្តែងទន់ ត្រីអណ្តែងរាំងត្រីខ្ញឹង ត្រីឆ្ពួញ ត្រីខ្យាន្ត ត្រីរ៉ស់ ត្រីក្រាញ់ ត្រីកញ្ចុះ ត្រីផ្ទោង ត្រីស្លាត ត្រីច្រកែង ត្រីតាអោន ត្រីឆ្លាំង ត្រីផ្ទោង ត្រីឆ្តោ ត្រីក្រុះ ត្រីស្រកាក្តាម ត្រីខ្មាន់....។ល។

**១៩៧. វិបត្តិដែលធ្វើឱ្យធ្លាក់ចុះក្នុងការនេសាទ និងមានការប្រែប្រួលសន្និធិត្រី:** នៅក្នុងសហគមន៍ដែលក្រុមការងារបានចុះធ្វើការអង្កេត នឹងសាកសួរជាមួយអ្នកធ្វើការនេសាទដែលមានចំនួន៣០គ្រួសារ នៅតំបន់នោះបានបង្ហាញឱ្យឃើញថាផលនេសាទរបស់ពួកគាត់មានការថយចុះស្ទើទាំងស្រុង (រកស្ទើមិនហូប)។ អំពីរូបភាពនៃវិបត្តិដែលកើតមានឡើងនៅក្នុងការនេសាទដែល ទទួលបានទិន្នផលខ្សត់ពីអូរមានដូចជា:

- ការធ្វើនេសាទដោយពឹងផ្អែកលើធម្មជាតិ ដែលធ្វើឱ្យការនេសាទរបស់ពួកគាត់ ទទួលបានផលនេសាទតិចទៅៗដែលបង្កជាផលអវិជ្ជមានសុវត្ថិភាពស្បៀងរបស់ពួកគាត់។
- ការឆ្មក់លួចចូលនៃអ្នកនេសាទពីតំបន់ខាងក្រៅដោយប្រើប្រាស់ឧបករណ៍ ខុសច្បាប់ (ឆក់ និងទំលាក់ថ្នាំពុលក្នុងអន្លងត្រីតាមអូរ)។
- ចំពោះប្រជាជនដែលពឹងផ្អែកលើរបរនេសាទមានការលំបាក នៅពេលដែលបរិមាណត្រីនៅក្នុងអូរ ប្រឡាយ ដែលពួកគាត់ធ្លាប់រកដោះស្រាយជីវភាពប្រចាំថ្ងៃនោះកាន់តែខ្សត់ទៅៗជូនកាលរកមួយថ្ងៃមិនគ្រប់សំរាប់ហូបផង។



Draft

**១៥៨. ហេតុប៉ះពាល់នៃការអនុវត្តន៍គំរោងអាជីវកម្មដាំដើមកៅស៊ូ ទៅលើជីវភាពរស់នៅរបស់សហគមន៍ និង ការទទួលយករបស់មូលដ្ឋានចំពោះគំរោងអភិវឌ្ឍន៍:** យោងលើលទ្ធផលនៃការសិក្សាពិគ្រោះយោបល់ជាមួយប្រជាជនដែលពាក់ព័ន្ធបានបង្ហាញនូវទស្សនៈយល់ដឹងពីរផ្សេងពីគ្នា:

**១៥៩.** ជាការពិតណាស់ដែលថាការអភិវឌ្ឍន៍តែងតែមានចំណុចអវិជ្ជមាន និងការខ្វែងគំនិតគ្នារវាងវិនិយោគិនជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ឬរវាងវិនិយោគិន និងអាជ្ញាធរជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ទៅលើផលប្រយោជន៍រួមមួយដែលទាំងអស់គ្នាមានសិទ្ធិក្នុងការទទួលបាន ប៉ុន្តែទិសដៅនិងគោលបំណងរួមរបស់ពួកយើង គឺសំដៅធ្វើយ៉ាងណាដើម្បីទទួលបាននូវការអភិវឌ្ឍន៍នៅកម្ពុជាមួយដែលធានាបាននូវកំណើននិងការអភិវឌ្ឍន៍ ជាពិសេសសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្ត្រ ដែលក្នុងនោះត្រូវពង្រឹង និងលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈអាចទទួលយកបានទាំងផ្នែកសង្គម-បរិស្ថាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ច។

**១៦០.** តំបន់ដីសម្បទាន **ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** មានទីតាំងស្ថិតនៅភូមិសាស្ត្រ ឃុំក្រយា និង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។ តាមរយៈការសំណេះសំណាល និងសំភាសន៍ រវាងក្រុមសិក្សានិងវាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាមួយប្រជានេសាទ ដែលធ្វើការនេសាទតាមអូរធំ និង អូរផ្សេងៗទៀតនៅក្នុងតំបន់នោះ បានឱ្យដឹងថាផលត្រីមានការថយចុះចាប់តាំងពី១០ឆ្នាំមុនមកម្លេះ ហើយផលនេសាទធ្លាក់ចុះខ្លាំងចាប់ពីឆ្នាំ២០០៨ ដោយសារមានការកើនឡើងនៃអ្នកនេសាទពីតំបន់ខាងក្រៅ លួចចូលមកនេសាទ និងមួយចំនួនទៀតតាមរយៈអ្នកធ្វើការនៅក្រុមហ៊ុន ដោយប្រើប្រាស់ឧបករណ៍ខុសច្បាប់ (ឆក់ និងទំលាក់ថ្នាំស្ពុយ)។

**១៦១.** តាមរយៈការជួបសំណេះសំណាលជាមួយអាជ្ញាធរ ឃុំ ភូមិ និងប្រជានេសាទនៅទីនោះពួកគាត់បានបញ្ជាក់ថា: ផលនេសាទមានការថយចុះពិតប្រាកដមែន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មូលហេតុដោយសារមានបទល្មើសនេសាទកើតឡើងញឹកញាប់ ហើយមិនមានកំលាំងសមត្ថកិច្ច ធ្វើការចុះបង្ក្រាបទេ។

**១៦២.** នៅក្នុងឱកាសចូលរួមពិគ្រោះយោបល់របស់ក្រុមការងារ **GCF** ជាមួយប្រជានេសាទក្នុងតំបន់ពួកគាត់បានចូលរួមមានមតិយោបល់ និងសំណូមពរមួយចំនួនដូចខាងក្រោម។ មតិចូលរួមយោបល់របស់ប្រជាពលរដ្ឋនៅឃុំបឹងល្វា ភូមិបឹងល្វាលើ និងភូមិអូរសោម ដែលក្រុមការងារបានធ្វើការជួបសំណេះសំណាលមាន:

- តាមប្រសាសន៍របស់លោក **ប៉ាត ឡេង** ប្រជាជនភូមិអូរសោម : ធនធានត្រីនៅតំបន់នេះមានច្រើនសំបូរបែបណាស់ពីមុនមក តែបច្ចុប្បន្ននេះ គឺមិនមានច្រើនទេគឺខ្សត់ខ្សោយណាស់ (ពិបាករក) ដែលជាមូលហេតុធ្វើឱ្យប្រជាជននៅទីនេះមានការលំបាកទៅលើម្ហូបអាហារ ដែលបញ្ហាទាំងនេះកើតឡើងដោយសារតែប្រព័ន្ធអូរនៅតំបន់នេះមានទឹកដក់ និងហូរជាប្រចាំ ដូចនេះការនេសាទគឺធ្វើទាំងរដូវវស្សា និងរដូវប្រាំង តែការនេសាទនេះមិនសំរាប់លក់ដូរទេគឺសំរាប់ទុកហូបតែប៉ុណ្ណោះ។

Draft

- តាមប្រសាសន៏របស់លោក **ក្រឹច សុភាព** មេភូមិបឹងល្វាលើ : ប្រជាជននៅតំបន់នេះ ធ្វើការនេសាទត្រីសំរាប់តែហូបប៉ុណ្ណោះ ព្រោះនៅតំបន់នេះ អូរសំបូរទៅដោយធនធានត្រីគ្រប់ប្រភេទ តែបច្ចុប្បន្ននេះ គឺមិនមានច្រើនទេគឺខ្សត់ខ្សោយណាស់ (ពិបាករក) ដែលជាមូលហេតុធ្វើឱ្យប្រជាជននៅទីនេះមានការលំបាកទៅលើម្ហូបអាហារដែលបញ្ហាទាំងនេះកើតឡើង ដោយសារតែអូរមានគេមកធ្វើការនេសាទដោយឧបករណ៍ខុសច្បាប់ (ឆក់) ប្រជាជននៅឃុំបឹងល្វា ភាគច្រើនគឺប្រើប្រាស់ទឹកស្ទឹង និង អូរផ្សេងនៅក្បែរភូមិ ដែលអូរទាំងនោះមានប្រភពទឹកមកពីតំបន់ភ្នំនៅភាគខាងជើងដីរបស់ក្រុមហ៊ុន ហូរចាក់ចូលទៅអូរធំ ដែលស្ថិតនៅភាគនិរតី នៃទីតាំងក្រុមហ៊ុន។ នៅរដូវវស្សាទឹកអូរទាំងនេះមានភាពល្អក់ខ្លាំងស្ទើរមិនអាចប្រើប្រានឡើយ តែដោយគ្មានជំរើស ពួកគាត់នាំគ្នាប្រើប្រាស់ទឹកអូរទាំងនោះទៅហើយពេលខ្លះក៏ប្រើទឹកភ្លៀង។ ដូចនេះសុំសំណូមពរធ្វើយ៉ាងណា ក្រុមហ៊ុនត្រូវគិតអំពីសុខភាពប្រជាពលរដ្ឋ ដែលរស់នៅអាស្រ័យដោយទឹកនៅតំបន់នេះផង បើពុំនោះទេប្រជាពលរដ្ឋនិងជួបនៅគ្រោះជំងឺជាមិនខាន ព្រោះប្រជាជនដែលរស់នៅតំបន់នេះក្រីក្រណាស់ហើយ បើមានជំងឺទៀតនោះមិនដឹងជាគិតយ៉ាងណានោះទេ។ ចំពោះធនធានត្រីវិញសង្កេតឃើញថា មានការថយចុះខ្លាំងមែនទែនរហូតនេសាទមិនបានហូបផងកុំថាឡើយ និយាយទៅដល់ការលក់ដូរនោះ បច្ចុប្បន្នត្រីទិញពីខេត្ត ឬចិនដឹកលក់តាមម៉ូតូ មកហូបវិញទេ វាផ្ទុយពេលមុនត្រីនៅទីនេះខ្វះខ្លាំងចាប់ពីឆ្នាំ២០០៨មក គឺរកមិនបានត្រីល្អហូបទេ អន្លុងត្រីនីមួយៗស្ងាត់មាត់ជ្រាប(អត់ត្រី)។ ដូចនេះ ក្នុងនាមអាជ្ញាធរសុំសំណូមពរដូចខាងក្រោម:

- សុំឱ្យក្រុមហ៊ុនជួយថែរក្សា ការពារទឹកឱ្យបានស្អាតជាប្រចាំ (កុំបង្ហូរជាតិពុលចូលក្នុងប្រព័ន្ធអូរ)
- ហាមសន្តិសុខ ឬទាហានដែលធ្វើការនៅក្នុងក្រុមហ៊ុនកុំឱ្យប្រើប្រាស់មធ្យោបាយបំពុលត្រី
- ក្រុមហ៊ុនត្រូវមានគោលការណ៍ ឬវិធានការចូលរួមទប់ស្កាត់ កុំប្រើឱ្យបការណ៏នេសាទខុសច្បាប់(ឆក់ ទំលាក់ថ្នាំស្ពុយ) ដែលទង្វើទាំងនោះ ធ្វើឱ្យបាត់បង់ និងផុតពូជត្រីនៅក្នុងតំបន់ទាំងមូល ។
- សុំឱ្យជំនាញមានសម្ថកិច្ចធ្វើការរឹតបន្តឹង បង្ក្រាបបទល្មើសនេសាទខុសច្បាប់ឱ្យមានប្រសិទ្ធិភាពខ្ពស់ បើមានការរាយការណ៍ពីប្រជាជនមូលដ្ឋាន សុំមន្ត្រីជំនាញទាំងនោះធ្វើការសហកាណ៍ចុះបង្ក្រាបឱ្យទាន់ពេលវេលា ដើម្បីសហការទប់ស្កាត់ទាន់សភាពការណ៍ ។

បច្ចុប្បន្នការនេសាទរបស់ប្រជាជននៅតំបន់នេះ គឺសំរាប់ធ្វើម្ហូបមួយពេលៗតែប៉ុណ្ណោះ ព្រោះធនធានត្រីក្នុងអូរទាំងនេះមានការថយចុះនិងខ្សត់ជាខ្លាំងមិនអាចនេសាទលក់ដូរបានទេ។

Draft

## ៤-៥ ធនធានសង្គម និងសេដ្ឋកិច្ច

**១៦៣.** លទ្ធផលនៃការធ្វើ PRA (ទំព័រ១៤១-១៤៦) កំណត់ហេតុ និងរបាយការណ៍សង្ខេបស្តីពីការពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត-ស្រុក មន្ទីរ និងសហគមន៍ពាក់ព័ន្ធ លើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ។

## ៤-៦ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

**១៦៤.** ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវទៅកាន់ឃុំក្រយាគឺជាជនបទទាំងស្រុង។ ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈខុសៗគ្នាទៅតាមទីប្រជុំជនខេត្ត ស្រុក និងជនបទ។ ប្រជាជនភាគច្រើនរស់ក្នុងតំបន់រណប (ឃុំក្រយា) ស្ទើរទាំងអស់ប្រកបរបរធ្វើស្រែ និងការរុករកផល-អនុផលព្រៃឈើ ក្រោយពីប្រមូលផលស្រូវ និងចំការរួច ។

**១៦៥.** តាមរយៈការចុះសិក្សាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅទីនោះ ប្រភពចំណូលសំខាន់របស់ពួកគាត់គឺអាស្រ័យលើមុខរបរធ្វើស្រែ (ទិន្នផលស្រូវ១-២តោនក្នុង១ហិកតា ១គីឡូក្រាមស្រូវលក់បានតំលៃ ១០០០ រៀល) និងចំការ (ចំងាយ៥ គ.ម ពីផ្ទះ) ។ ចំណែកមុខរបរបន្ទាប់បន្សំផ្សេងទៀតគឺ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ស៊ីឈ្នួលដកស្ទូង ដាំដំឡូងមី ដំឡូងជ្វា សណ្តែក ត្រសក់ ស្វាយចន្ទី អំពៅ ចេក ពោត និងការ ចូលព្រៃដើម្បីទាញផលពីអនុផលព្រៃឈើដូចជា កាប់កូនឈើរបងផ្ទះ កាប់ឈើធ្វើជន្ទល់ធ្វើសំណង់ផ្ទះថ្ម ឬព្រះវិហារ ឈើគ្រាក់ ដងជំរ បោចវល្លិ៍ វាយផ្តៅ សឹង បេះផ្លែឈើ (ផ្លែគុយ) រកទំពាំង ដកផ្សិត ជីកដំឡូងទៀន កាប់អុស (តែកម្រមានឈ្មួញចូលមកទិញណាស់) ដុតធ្យូង និងធ្វើអាជីវកម្មអារឈើ ខ្នាតតូចជាដើម។ ការចិញ្ចឹមគោក្របីបន្តិចបន្តួចរបស់ពួកគាត់ គឺសំរាប់ប្រើប្រាស់ជាមធ្យោបាយធ្វើស្រែ ចំការ ផង និងដឹកឈើផង។ ចំណែកមាន់ និងជ្រូកវិញគេចិញ្ចឹមជាលក្ខណៈប្រពៃណី មានឈ្មួញមកទិញដល់ ភូមិតែម្តង ដោយមាន់១គ.ក្រថ្លៃ ១៥០០០-១៨០០០រៀល ប៉ុន្តែគ្រួសារភាគច្រើនគ្មានមាន់លក់ទេ។ ការចិញ្ចឹមជ្រូកវិញ ក៏មិនសូវជាចិញ្ចឹមច្រើន ដោយសារកូនជ្រូកថ្លៃ ហើយចំណីក៏ថ្លៃទៀត គ្រួសារខ្លះចិញ្ចឹម១-២ក្បាល ឯខ្លះ ទៀតមិនមានចិញ្ចឹមទេ។ ពួកគាត់ចិញ្ចឹមជ្រូកមិនមែនជាលក្ខណៈអាជីវកម្មទេ គឺគ្រាន់សំរាប់ដោះស្រាយពេលរវល់បុណ្យទាន ឬការកូនចៅតែប៉ុណ្ណោះ។ ក្រៅពីមុខរបរធ្វើស្រែចំការ មានបងប្អូនខ្លះមានមុខរបរលក់ ចាប់ហួយសំរាប់ផ្គត់ផ្គង់ជីវភាពបន្ថែម ប៉ុន្តែការលក់ដូររបស់គាត់មិនសូវជាកាក់កបប៉ុន្មានទេ ខ្លះអស់ដើម ដោយសារគេជំពាក់ច្រើនពេក វាមិនដូចនៅទីផ្សារឡើយ។

**១៦៦.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រ

Draft

នៅក្នុងខេត្តកំពង់ធំមាន : ២៩.១០ភាគរយ (១៥៨,៩០៣នាក់) លើចំនួនប្រជាជនសរុប ៦២៤,៨៤៦នាក់ ក្នុងនោះមាន ៦២១.៨៣៣នាក់ ឬស្មើនឹង ៩៩ភាគរយ រស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀងអង្គការសហប្រជាជាតិឆ្នាំ ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ ២០០៤)។ ជាទូទៅពួកគាត់បានចូលសាលាជាមធ្យមត្រឹមកំរិតថ្នាក់ទីប្រាំតែប៉ុណ្ណោះ។

**១៦៧.** គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងសហគមន៍ដាច់ស្រយាលទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា។ ការសិក្សាបានបង្ហាញឱ្យឃើញថា អ្នកភូមិដែលរស់នៅតាមដងផ្លូវក៏ដូចជាប្រជាជនដែលរស់នៅតាមភូមិក្រយា ភូមិដងក្ដារ ភូមិតាម៉ិញ ភូមិសុភមង្គល ភូមិត្រពាំងព្រីង និងភូមិទក់ ភូមិអូរទឹកថ្លា ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំដែរ ពុំបានទទួលការផ្គត់ផ្គង់ អគ្គិសនីជាមូលដ្ឋានទេ។ មានប្រជាជនចំនួនតិចតួចគ្រួសារណាស់ដែលមានម៉ាស៊ីនភ្លើងខ្លួនឯងប្រើក្នុងពេល ដែលគ្រួសារភាគច្រើនទៀតមានលទ្ធភាពប្រើប្រាស់អាគុយ និងចង្កៀងប្រេងកាតសំរាប់បំភ្លឺនៅពេលយប់។ រីឯ ប្រភពថាមពលសំខាន់សំរាប់ការចំអិនអាហាររបស់ពួកគាត់គឺអុស និងធ្យូង។

**១៦៨.** ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើនគឺប្រើប្រាស់ផ្លូវជាតិលេខ៦ ដែលជាផ្លូវយ៉ាងសំខាន់នៅក្នុងតំបន់នេះ។ ផ្លូវជាតិលេខ៦បានចាប់ផ្ដើមពីភ្នំពេញ ដោយឆ្លងកាត់ខេត្តកណ្ដាល ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ហើយចប់នៅកាន់មាត់ច្រកអន្តរជាតិប៉ោយប៉ែត ក្នុងស្រុកអូរជ្រៅ។ រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅកាន់ទីប្រជុំជនឃុំក្រយាជាផ្លូវដីមានក្រាលក្រួសក្រហមដោយអន្លើ (ពីទីប្រជុំជនកំពង់ថ្មទៅម្តុំទំនប់ទឹក១មករា) បន្ទាប់មកគឺជាផ្លូវក្រាលក្រួសក្រហម ហើយនៅត្រង់កំណាត់ផ្លូវនេះ ផ្លូវមានសភាពទ្រុឌទ្រោមនិងខូចខាតដោយកន្លែង។ ចំណែកឯការធ្វើដំណើរពីទីប្រជុំជនឃុំក្រយាទៅកាន់ភូមិដទៃទៀតក៏មានការលំបាកខ្លាំងដែរ។ ដោយសារតែការធ្វើដំណើរចេញចូលមានលក្ខណៈអន់ថយ ដូច្នេះហើយទើបធ្វើអោយការប្រាស្រ័យទាក់ទងរវាងសហគមន៍ទាំងនេះជាមួយនឹងតំបន់ខាងក្រៅ ពុំមានលក្ខណៈទូលំទូលាយ និងទទួលបានការយកចិត្តទុកដាក់តិចតួចពីបណ្ដាភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ ដែលក្នុងនោះមានការផ្គត់ផ្គង់ទឹកស្អាត ថាមពល សាលារៀន និងមណ្ឌលសុខភាពជាដើម។

## ៤-៧ ធនធានសង្គម និងវប្បធម៌

**១៦៩.** នៅក្នុងភូមិសាស្ត្រដែលក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** បានស្នើសុំមានទីតាំងស្ថិតនៅក្នុងឃុំក្រយា ស្រុក សន្ទុក ខេត្តកំពង់ធំ។ ឃុំក្រយា មានប្រជាជន ១៨៩៨គ្រួសារ ប្រជាជនសរុប ៩៤១៨នាក់ ស្រី ៤៩១៨នាក់ រស់នៅក្នុងភូមិចំនួន ១០ ដូមាននៅក្នុងតារាង ៤-៩ ខាងក្រោមនេះ :

Draft

**តារាង៤-៩: តារាងស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០១១ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋសរុប(នាក់) | ចំនួនស្រីសរុប (នាក់) |
|---|---|---|---|---|
| ១ | ដងក្ដារ | ៥៤៨ | ២៣៩៩ | ១២២៨ |
| ២ | ក្រយា | ២៦៧ | ១២៨២ | ៦៥៨ |
| ៣ | សុភមង្គល | ២២៣ | ១០៥២ | ៥៣៨ |
| ៤ | តាម៉ិញ | ២៥៦ | ១៣១៩ | ៦៧៧ |
| ៥ | ត្រពាំងព្រីង | ១៦៨ | ៨៦២ | ៤៤៣ |
| ៦ | ទក់ | ២៧៧ | ១២៥៦ | ៦៥២ |
| ៧ | ថ្មសំលៀង | ១៧២ | ៨១០ | ៤០២ |
| ៨ | ត្រពាំងឫស្សី | ១២៩ | ៤២៩ | ២១៨ |
| ៩ | សិរីមង្គល | ២០៦ | ២១៨២ | ១០៨២ |
| ១០ | អូរទឹកថ្លា | ២០៩ | ៨៦៣ | ៤០២ |
| **សរុបរួម** | | **២៤៥៥** | **១២៤៥៤** | **៦៣០០** |

**១៧០.** ក្រុមការងារធ្វើការសិក្សាវាយតំលៃអំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងភូមិសាស្ត្រ ដែលក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** បានស្នើសុំមានទីតាំងស្ថិតក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្ត កំពង់ធំ។ ការសិក្សាស្រាវជ្រាវបានឱ្យដឹងថាភូមិចំនួន១០ នៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ក្នុងនោះមានៈ ភូមិដងក្ដារមានចំនួន ៥៤៨គ្រួសារ ភូមិក្រយាមានចំនួន ២៦៧គ្រួសារ ភូមិសុភមង្គលមានចំនួន ២២៣គ្រួសារ ភូមិតាម៉ិញមានចំនួន ២៥៦គ្រួសារ ភូមិត្រពាំងព្រីងមានចំនួន ១៦៨គ្រួសារ ភូមិទក់មានចំនួន ២៧៧គ្រួសារ ភូមិថ្មសំលៀង (ភូមិឧបសម្ព័ន្ធរបស់ភូមិដងក្ដារ) មានចំនួន ១៧២គ្រួសារ ដែលបានរស់នៅតំបន់ខាងលិចដីសម្បទាន ភូមិត្រពាំងឫស្សីមានចំនួន។ ប៉ុន្តែ ភូមិដែលមានការពាក់ព័ន្ធគឺភូមិអូរទឹកថ្លា។

**១៧១.** លំនាំនៃការតាំងទីលំនៅមានលក្ខណៈជាជនបទគឺ (១) ការតាំងទីលំនៅតាមសងខាងនៃបណ្ដោយ ផ្លូវដីចាប់ពីទីប្រជុំជនកំពង់ថ្មរហូតដល់ទីប្រជុំជនឃុំក្រយា និង (២) មានការតាំងទីជាភូមិដាច់ស្រយាចំងាយប្រមាណ ៤០គមពីឃុំ គឺ(ភូមិអូរទឹកថ្លា) ក្នុងនោះមានប្រជាជនចំនួន ២០៩គ្រួសាររស់នៅ។

**១៧២.** យោងទៅលើលទ្ធផលនៃការសិក្សាផ្នែកសេដ្ឋកិច្ច-សង្គម នៅលើទីតាំងគំរោងវិនិយោគរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** ពុំមានសំណង់ប្រវត្តិសាស្ត្រ ឬសម្បត្តិវប្បធម៌ និងទីសក្ការៈបូជារបស់សហគមន៍មូលដ្ឋានទេ។

**របាយប្រជាជន**

**១៧៣.** ការសិក្សានៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បានបង្ហាញថា ក្នុងតំបន់ស្នើសុំដីសម្បទានមាន ប្រជាជនសរុបចំនួន ១៨៩៨គ្រួសារ ស្មើនិង ៩៤១៨នាក់ ក្នុងនោះ៤៩១៨នាក់ជានារីភេទ (ទិន្នន័យស្រង់ចេញពី ឯកសារស្ថិតិខែធ្នូឆ្នាំ២០១០របស់មេឃុំក្រយា) ។ ការតាំងទីលំនៅរបស់ពួកគាត់គឺស្ថិតនៅក្នុងតំបន់ទ្រនាប់ ដែលក្នុងនោះមានភូមិចំនួន១០គឺ: (១)ភូមិដងក្ដារ មានប្រជាជន ៥៤៨គ្រួសារ ប្រជាជន សរុប២៣៩៩នាក់ ស្ត្រី១២២៨នាក់ (២)ភូមិក្រយា មានប្រជាជន ២៦៧គ្រួសារ ប្រជាជនសរុប ១២៨២នាក់ ស្ត្រី ៦៥៨នាក់ (៣)ភូមិសុភមង្គល មានចំនួន ២២៣ គ្រួសារ ប្រជាជនសរុប ១០៥២នាក់ ស្ត្រី ៥៣៨នាក់ (៤)ភូមិតាម៉ិញ មានចំនួន២៥៦គ្រួសារ ប្រជាជន សរុប ១៣១៩នាក់ ស្ត្រី ៦៧៧នាក់ (៥)ភូមិត្រពាំងព្រីង មាន១៦៨គ្រួសារ ប្រជាជនសរុបមានចំនួន ៨៦២នាក់ ស្ត្រី ៤៤៣នាក់ (៦)ភូមិទក់ មាន ២៧៧គ្រួសារ ប្រជាជនសរុប ១២៥៦ នាក់ ស្ត្រី ៦៥២នាក់ (៧) ភូមិថ្មសំលៀង មានចំនួន ១៧២គ្រួសារ ប្រជាជនសរុប ៨១០នាក់ ស្ត្រី ៤០២នាក់ (៨)ភូមិត្រពាំងឫស្សី មាន ១២៩គ្រួសារ ប្រជាជនសរុប ៤២៩គ្រួសារ ស្ត្រី ២១៨នាក់ (៩) ភូមិសិរីមង្គល មានចំនួន ២០៦គ្រួសារ ប្រជាជន សរុប ២១៨២នាក់ ស្ត្រី១០៨២នាក់ (១០)ភូមិអូរទឹកថ្លា មាន ២០៩គ្រួសារ ប្រជាជនសរុប ៨៦៣នាក់ ស្ត្រី ៤០២នាក់។ ក្នុងចំណោមភូមិទាំង១០មានបួនភូមិដែលមិនទាន់មានការទទួល ស្គាល់ពីក្រសួងមហាផ្ទៃ ប៉ុន្តែបច្ចុប្បន្នឃុំបានស្នើសុំបង្កើតភូមិថ្មីនេះទៅដល់ស្រុកហើយ ក្នុងនោះមានភូមិថ្ម សំលៀង ឬភូមិថ្មី(ភូមិឧបសម្ព័ន្ធរបស់ភូមិដងក្ដារជាភូមិចាស់)មានចំនួន ១៧២គ្រួសារ (៨១០នាក់) ភូមិ ត្រពាំងឫស្សី មាន ១២៩គ្រួសារ ប្រជាជនសរុប (៤២៩នាក់) ភូមិសិរីមង្គល មានចំនួន ២០៦គ្រួសារ (២១៨២នាក់) និងភូមិអូរទឹកថ្លា មានចំនួន ២០៩នាក់ (៨៦៣នាក់) ដែលរស់នៅភាគខាងលិចនៃតំបន់ ដីសម្បទាន។ សូមបញ្ជាក់ផងដែរថា មានភូមិ១ដែលមានភូមិសាស្ត្រ ពាក់ព័ន្ធទៅនឹងតំបន់ស្នើសុំដីសម្បទាន នេះ គឺភូមិអូរទឹកថ្លា ដែលមានទីតាំងស្ថិតនៅភាគខាងកើតជាប់នឹង ដីស្នើសុំ។

**លក្ខណៈប្រជាសាស្ត្រ**

**១៧៤.** ទំនៀមទំលាប់ និងប្រពៃណីនៃការរស់នៅរបស់ប្រជាជនក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលពាក់ព័ន្ធនឹងទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ពួកគាត់ រស់នៅអមសង្ខាងផ្លូវក្រាលក្រួសក្រហមមួយដែលបែកចេញពីផ្លូវជាតិលេខ៦ ត្រង់មុំហួសស្ពានកំពង់ថ្មបន្តិច ខាងស្ដាំដៃ (ទិសដៅភ្នំពេញទៅកំពង់ធំ)។ ការរស់នៅរបស់ពួកគាត់នៅទីនោះ មិនខុសពីការរស់នៅរបស់ ប្រជាជនខ្មែរយើង នៅតាមជនបទផ្សេងៗទៀតឡើយគឺប្រកបរបរធ្វើស្រែ ចំការ (ស្រូវ សណ្ដែក ត្រសក់ ស្វាយចន្ទី ដំឡូងមី ដំឡូងជ្វា អំពៅ ចេក ពោត) ការលក់ដូរបន្តិចបន្តួច ធ្វើអាជីវកម្មអារឈើខ្នាតតូច

និងមុខរបរបន្ទាប់បន្សំមួយចំនួនទៀតដូចជា ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ការទាញយកអនុផលពីព្រៃឈើ ឡើងគ្នោត និងស៊ីឈ្នួលដកស្ទូង សំរាប់ផ្គត់ផ្គង់ជីវភាពបន្ថែម ។

**១៧៥.** ចំពោះជនបង្គោល ឬអ្នកដើរតួនាទីសំខាន់នៅក្នុងការទ្រទ្រង់ជីវភាពគ្រួសារស្ទើរតែទាំងអស់ជាបុរសភេទ។ ចំណែកលទ្ធភាពទទួលការអប់រំរបស់មេគ្រួសារនៅក្នុងតំបន់នេះវិញ (តំបន់ដែលពាក់ព័ន្ធនឹងទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន) មានកំរិតទាប (ភាគច្រើនថ្នាក់ទី៣-៤ថ្មី) បើប្រៀបធៀបនឹងលទ្ធភាពដែលមេគ្រួសារនៅតាមទីក្រុង និងតាមទីប្រជុំជនធំៗបានទទួល។ ក្នុងភូមិអូរទឹកថ្លា អ្នកចេះអានចេះសរសេរពុំសូវមានទេ សូម្បីតែប្រធានភូមិគាត់មិនសូវចេះអក្សរប៉ុន្មានផង នេះដោយសារនៅក្នុងភូមិពុំទាន់មានសាលារៀននៅឡើយ។ ចំណែកឯឃុំវិញ មានត្រឹមតែកំរិតអនុវិទ្យាល័យប៉ុណ្ណោះ បើចង់បន្តការសិក្សា គឺត្រូវធ្វើដំណើរឆ្ងាយ (វិទ្យាល័យកំពង់ថ្ម) ដែលពួកគាត់មិនអាចមានលទ្ធភាពគ្រប់គ្រាន់។

**១៧៦.** តាមរបាយការណ៍របស់ថ្នាក់ដឹកនាំឃុំ (ដោយផ្ទាល់មាត់របស់លោក កែវ ឆេង មេឃុំក្រយា និងលោក សំ អ៊ី ស្មៀនឃុំក្រយា) បានឱ្យ ដឹងថា នៅក្នុងភូមិមួយចំនួនក្នុងឃុំក្រយាមានអ្នកចំណូលថ្មីមករស់នៅ ដែលភាគច្រើនមកពីខេត្តកំពង់ចាម តាកែវ និង កំពង់ស្ពឺ។ ឧទាហរណ៍ជាក់ស្តែង នៅភូមិក្រយាមានអ្នកចំណូលថ្មីចំនួន ១៦គ្រួសារ ភូមិដងក្តារ មានអ្នកចំណូល ថ្មីចំនួន៨៣គ្រួសារ និងភូមិសុភមង្គលមានអ្នកចំណូលថ្មីចំនួន៦គ្រួសារ។ ចាប់តាំងពីមានអ្នកចំណូលថ្មីចូលមក រស់នៅធ្វើអោយតំបន់នេះកើតអសន្តិសុខជាហូរហែរ ដូចជាមានអំពើចោរកម្ម (លួចមង ទ្រូ គោ ក្របី ម៉ូតូ។ល។) ជាដើម។ ក្រុមការងារពុំសង្កេតឃើញមានជនជាតិភាគតិចរស់នៅទីនោះច្រើនឡើយ មានតែជនជាតិវៀតណាមចំនួន០២គ្រួសារប៉ុណ្ណោះ។ ដោយឡែក តាមការរាយការណ៍ (តាមទូរសព្ទ) របស់លោក ឌឿប សារ៉ន មេភូមិអូរទឹកថ្លា បានបង្ហាញថា ប្រជាជនរស់នៅក្នុងភូមិរបស់គាត់ចំនួន ២០៩ គ្រួសារ ភាគច្រើនជាអ្នករស់នៅក្នុងស្រុក ឯចំណូលស្រុកមានតិចទួច ប្រកបរបរធ្វើស្រែចំការដាំដំណាំ ដូចជាស្រូវ ដំឡូងមី ស្វាយចន្ទី និងនេសាទត្រីជាលក្ខណៈគ្រួសារជាមុខរបរបន្ទាប់បន្សំ។

### ស្ថានភាពផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់គ្រួសារ

**១៧៧.** ផ្ទះសំបែងរបស់ប្រជាពលរដ្ឋនៅភូមិអូរទឹកថ្លាស្ទើរតែទាំងអស់ធ្វើអំពីឈើប្រក់ស្បូវ មានជញ្ជាំងស្លឹក សង់ផុតពីដីកំពស់១-១,៥ម ទំហំ១២-៤០$ម^2$ ទៅតាមលទ្ធភាព និងចំនួនសមាជិករបស់ក្រុមគ្រួសារ។ តាមសៀវភៅទិន្នន័យភូមិឆ្នាំ២០០១០ បានឱ្យបញ្ជាក់ផងដែរថា មានផ្ទះប្រក់ក្បឿងតែ១ខ្នងប៉ុណ្ណោះនៅក្នុងភូមិទាំងមូល ក្រៅពីនោះមានផ្ទះប្រកស្បូវ ឬស្លឹកមានចំនួន ១៨៣ផ្ទះ និងផ្ទះប្រកហ្វីប្រូស៊ីម៉ងត៍ ចំនួន២៥ផ្ទះ ក្នុងចំណោមផ្ទះសរុប ២០៩ផ្ទះ ។

**១៧៨.** ដោយភូមិអូរទឹកថ្លានៅជាប់នឹងផ្លូវដី ពួកគាត់មានលទ្ធភាពប្រើប្រាស់មធ្យោបាយធ្វើដំណើរដូចជា ម៉ូតូ គោយន្ត រទេះគោ និងកង់ (ច្រើនបំផុត)។ សៀវភៅទិន្នន័យភូមិអូរទឹកថ្លា ខែ ធ្នូ ឆ្នាំ ២០១០បានបង្ហាញថា



Draft

ក្នុងភូមិអូរទឹកថ្លាមានម៉ូតូចំនួន ៧៩ គ្រឿង កង់ចំនួន ៣០គ្រឿង គោយន្តប្រើប្រាស់សំរាប់ធ្វើស្រែចំការផង និងដឹកឈើផងចំនួន២គ្រឿង និងប្រជាជនចំនួន ៣៤ គ្រួសារ មានទូរទស្សន៍ និងប្រហែល ៥០% មានវិទ្យុប្រើប្រាស់។ ក្រៅពីនេះ មានប្រជាជនមួយចំនួន (១២ គ្រួសារ) មានគោ ក្របី ៥៤ក្បាល ក្នុងនោះមានគោប្រើប្រាស់ជាកំលាំងសំរាប់ធ្វើស្រែចំការចំនួន ៣នឹម។ រីឯមេ គោវិញច្រើនតែបងប្អូនគេពីខាងក្រោយកមកឱ្យចិញ្ចឹមដើម្បីប្រវ៉ាស់យកកូន។ ឯជ្រូក និងមាន់ទា មានការចិញ្ចឹមជាលក្ខណៈគ្រួសារ មិនមានចិញ្ចឹមជាអាជីវកម្មឡើយ។

**សេវាធារណៈ**

**១៧៩.** គួរបញ្ជាក់ថាលទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈ (គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី អប់រំ និងសុខាភិបាល) នៅក្នុងតំបន់ដែលមានការពាក់ព័ន្ធនឹងទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុននៅមានកំរិត។ ភាពខ្វះខាតនៃសេវាសាធារណៈទាំងអស់នេះបានបង្កការលំបាកសព្វបែបយ៉ាងចំពោះពួកគាត់នៅទីនោះ ហើយវាក៏ជាបន្ទុកដ៏ធ្ងន់ធ្ងរសំរាប់រាជរដ្ឋាភិបាលផងដែរ។

**១៨០.** ផលលំបាករបស់ពួកគាត់រួមមាន ការធ្វើដំណើរត្រូវចំណាយពេលយូរដោយសារផ្លូវទៅកាន់ភូមិមានភាពលំបាក និងខូចដោយអន្លើ១ និងមិនទាន់មានស្ពានឆ្លងកាត់ត្រឹមត្រូវនៅឡើយ។ ការប្រើប្រាស់ទឹកស្អាតនៅមានកំរិត ដោយពួកគាត់ទាំងអស់ប្រើទឹកអណ្តូងជីកដៃគ្មានដាក់លូ និងទឹក ស្ទឹង។ ចំណែកបញ្ហាបណ្តាញអគ្គិសនីនៅតំបន់គំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចនេះវិញ គឺពុំទាន់មាននៅឡើយ ទេ។

**១៨១.** ចំពោះលទ្ធភាពនៃការប្រើប្រាស់ទឹកស្អាតនៅមានកំរិតទាបនៅឡើយ។ ក្រុមការងារបានសង្កេតឃើញថាមានតែអណ្តូងលូមិនរៀបតដ្ឋ ១៧០អណ្តូង នៅក្នុងភូមិ ដែលបានជីកតាមគ្រួសារនិមួយ១។ ប្រជាជនភាគច្រើនប្រើប្រាស់ទឹកអណ្តូងជីកដៃគ្មានលូសំរាប់ទទួលទាន ចំណែកសំរាប់មុជ និងបោកសំលៀកបំពាក់ ពួកគាត់ប្រើប្រាស់អូរទឹកថ្លា និងទឹកស្ទឹងជីនិតដែលស្ថិតនៅខាងកើតភូមិ។ រីឯនៅរដូវវស្សាវិញ ពួកគាត់ប្រើប្រាស់ទឹកភ្លៀង។

**១៨២.** រីឯថាមពលសំរាប់បំភ្លឺវិញគឺ ចង្កៀងប្រេងកាត និងអាគុយ ដោយមានតែគ្រួសារប្រមាណ៧០% មានលទ្ធភាពប្រើប្រាស់អាគុយសំរាប់បំភ្លឺនៅពេលយប់។ តាមប្រសាសន៍របស់លោក ឡេប សារ៉ន មេភូមិអូរទឹកថ្លាបានឱ្យដឹងថា បើតាមការគិតគូរមើលឃើញថា ការចំណាយទៅលើប្រេងកាតក្នុង១ខែ១ វាមានតម្លៃ ថ្លៃជាងតម្លៃបញ្ចូលអាគុយផង ក៏ប៉ុន្តែដោយសារគ្រួសារភាគច្រើនគ្មានប្រាក់សម្រាប់ទិញអាគុយ ទើបពួកគាត់នៅទ្រាំប្រើចង្កៀងប្រេងកាតដូច្នេះ។ ចំពោះថាមពលក្នុងការចំអិនអាហាររបស់ពួកគាត់គឺអុសដែលពួកគាត់ កាប់មកពីព្រៃនៅក្បែរភូមិ និងធ្យូងដែលសល់ពីពួកគាត់ដុតសំរាប់លក់។

Draft

**១៨៣.** វិស័យអប់រំនៅក្នុងតំបន់ដែលពាក់ព័ន្ធ (ភូមិអូរទឹថ្លា) នេះគឺស្ថិតនៅកំរិតសូន្យ ដោយនៅទីនោះពុំមានសាលាបឋមសិក្សានៅឡើយ (មានសាលាប្រក់ស្បូវមួយបន្ទប់ រៀនត្រឹមថ្នាក់ទី១-២ ដែលសាងសង់ឡើងដោយមូលនិធិប្រជាជនក្នុងភូមិតែគ្មានគ្រូ ដែលជាបញ្ហាចោទខ្លាំង ពួកគាត់បានសុំទៅខាងឃុំស្រុកដែរ ពុំឃើញមានធ្លាក់អ្វីមកវិញ។ ចំពោះអ្នកមានមានលទ្ធភាព ឬមានបងប្អូននៅខាងក្រៅគេច្រើនផ្ញើរកូនឱ្យទៅរៀននៅទីនោះ ដូចជាខាងកំពង់ចាម នៅកំពង់ថ្ម និងកំពង់ធំ។ ឪពុកម្តាយនៃកូនសិស្សម្នាក់ៗទៀតសោតក៏មានការលំបាកក្នុងការបង់ប្រាក់ចំនួន១000 រៀលក្នុង១ខែ សម្រាប់ជួលគ្រូឯកជនមកបង្រៀន ដែលជាហេតុធ្វើឱ្យសាលានោះគ្មានការថែទាំត្រឹមត្រូវ និងមានសភាពទ្រុឌទ្រោម រហែករហុយយ៉ាងខ្លាំង) ដូច្នេះកុមារទាំងអស់មិនបានចូលរៀន។ តាមការរាយការណ៍ របស់លោក ឡេប សារ៉ន មេភូមិភូមិអូរទឹកថ្លា បានបញ្ជាក់ថាបើសិនមានគ្រូអាចរៀនត្រឹមថ្នាក់ទី១-៤ ពីព្រោះកូនខ្លះវាធ្លាប់រៀន ពីមុនមកដល់ពេលម៉ែឪខ្សត់មករស់នៅទីនេះពួកគេក៏បានឈប់រៀនអស់ទៅ។

**១៨៤.** ទាក់ទងនឹងបញ្ហាសុខភាព នៅក្នុងភូមិអូរទឹកថ្លាគ្មានប៉ុស្តិ៍សុខភាពទេ មានតែគ្រូពេទ្យស្ម័គ្រចិត្តជម្ងឺគ្រុនចាញ់ប្រចាំភូមិតែប៉ុណ្ណោះ។ នៅពេលនរណាម្នាក់មានជំងឺ ពួកគាត់ត្រូវធ្វើដំណើរទៅរកពេទ្យឯកជនជួនកាលទៅមណ្ឌលសុខភាព ដែលមានចំងាយប្រហែល៤៤គ.ម (មណ្ឌលសុខភាពល្អក)។ បើក្នុងករណីធ្ងន់ធ្ងរត្រូវបញ្ជូនទៅមន្ទីរពេទ្យនៅកំពង់ថ្ម (ចំងាយ៥0គ.ម) ឬមន្ទីរពេទ្យបង្អែកកំពង់ស្វាយ ឬទៅពេទ្យខេត្តកំពង់ចាម និងមន្ទីរពេទ្យបង្អែក ខេត្តតែម្តង ទៅតាមលទ្ធភាពដែលពួកគាត់មាន។

## ប្រភពធនធានធម្មជាតិ និងលទ្ធភាពនៃការទទួលយកធនធានធម្មជាតិ

**១៨៥.** ថ្វីត្បិតតែការរស់នៅ និងកំរិតជីវភាពរបស់ប្រជាជននៅតំបន់នេះនៅមានកំរិតទាប តែលទ្ធភាពរបស់ពួកគាត់ក្នុងការប្រើប្រាស់ធនធានធម្មជាតិមានកំរិតខ្ពស់។ ការសិក្សាបានបង្ហាញថា ប្រជាជនរស់នៅតំបន់នេះបានទទួលផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលពីអនុផលព្រៃឈើមួយចំនួនដូចជា កាប់កូនឈើរបងផ្ទះ ឈើធ្វើជន្ទល់ធ្វើសំណង់ផ្ទះថ្មឬព្រះវិហារ ឈើគ្រាក់ ដងជ័រ បោចវល្លិ៍ វាយផ្តៅ សឺង បេះផ្លែឈើ (ផ្លែគុយ) រកទំពាំង ដកផ្សិត ជីកដំឡូងទៀន កាប់អុស ដុតធ្យូងសំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។

**១៨៦.** ពួកគាត់ក៏អាចទាញយកផលត្រីពីក្នុងស្ទឹងដែលស្ថិតនៅក្នុងតំបន់ដែលស្នើសុំដោយគំរោង ព្រមទាំងអាចទាញយកផលអាពីងពីព្រៃនោះផងដែរ។ ជារៀងរាល់ព្រឹក ទាំងប្រុសទាំងស្រីគ្រប់ក្រុមគ្រួសារនៅក្នុងតំបន់ដែលពាក់ព័ន្ធនេះ តែងតែចូលព្រៃដើម្បីទាញយកអនុផលព្រៃឈើ និងកាប់ឆ្ការព្រៃបន្ថែមដើម្បីរានដីធ្វើកសិកម្ម។ ប៉ុន្តែបច្ចុប្បន្ននេះមានព្រៃសំរាប់ពួកគាត់ចូលទៅរកទៀតទេ ពីព្រោះក្រុមហ៊ុនបានធ្វើការវិនិយោគដាំដើមកៅស៊ូអស់ទៅហើយ មានតែនៅក្បែរៗភូមិតិចទួចប៉ុណ្ណោះ តែក៏វានៅជិតពាក់ពន្ធ័ជាមួយដីក្រុមហ៊ុនស្នើ

សុំទៀត ចំនួន ៥២៩ហិកតា ដែលមិនទាន់បានដោះស្រាយជាមួយប្រជាពលរដ្ឋ។ ហើយរាល់ថ្ងៃនេះប្រជាពលរដ្ឋនៅតែធ្វើ ក្រុមហ៊ុនក៏គេមិនទាន់និយាយថាយ៉ាងម៉េចដែរ។

**ប្រភពចំណូលសំខាន់របស់គ្រួសារ**

**១៨៧.** តាមរយៈការផ្តល់ពតិមានដោយផ្ទាល់ជាមួយមេភូមិប្រជាពលរដ្ឋនៅទីនោះ ប្រភពចំណូលសំខាន់របស់ពួកគាត់ គឺអាស្រ័យលើមុខរបរធ្វើស្រែ (ទិន្នផលស្រូវ១-១,៦តោន ក្នុង១ហិកតា ១គីឡូក្រាមស្រូវលក់បានតំលៃ ១០០០ រៀល) និងចំការ (ចំងាយ ២-៣ គ.ម ពីផ្ទះ)។ ចំណែកមុខរបរបន្ទាប់បន្សំផ្សេងទៀតគឺការចិញ្ចឹមសត្វជា លក្ខណៈគ្រួសារ ស៊ីឈ្នួលដកស្ទូង ដាំដំឡូងមី ដំឡូងជ្វា សណ្តែក ត្រសក់ ស្វាយចន្ទី អំពៅ ចេក ពោត និងការចូល ព្រៃដើម្បីទាញផលពីអនុផលព្រៃឈើដូចជា កាប់កូនឈើរបងផ្ទះ កាប់ឈើធ្វើជន្ទល់ធ្វើសំណង់ផ្ទះថ្ម ឬព្រះ វិហារ ឈើគ្រាក់ ដងជ័រ បោចវល្លិ៍ វាយផ្តៅ សឹង បេះផ្លែឈើ (ផ្លែគុយ) រកទំពាំង ដកផ្សិត ជីកដំឡូងទៀន កាប់អុស (តែកម្រមានឈ្មួញចូលមកទិញណាស់) ដុតធ្យូង ជាដើម។ ការចិញ្ចឹមគោក្របី បន្តិចបន្តួចរបស់ពួកគាត់ គឺសំរាប់ប្រើប្រាស់ជាមធ្យោបាយធ្វើស្រែ។ ចំណែកឯមាន់ និងជ្រូកវិញគេចិញ្ចឹមជាលក្ខណៈប្រពៃណី មានឈ្មួញមកទិញដល់ដល់ភូមិតែម្តង ដោយមាន់១គ.ក្រថ្លៃ១២០០០រៀល ប៉ុន្តែគ្រួសារភាគច្រើនគ្មានមាន់លក់។ ការចិញ្ចឹមជ្រូក វិញក៏មិនសូវជាចិញ្ចឹមច្រើន ដោយសារកូនជ្រូកថ្លៃ ហើយចំណីក៏ថ្លៃទៀត គ្រួសារខ្លះចិញ្ចឹម១-២ក្បាល ឯខ្លះទៀតមិនមាន ចិញ្ចឹមទេ។ ពួកគាត់ចិញ្ចឹមជ្រូកមិនមែនជាលក្ខណៈអាជីវកម្មទេ គឺគ្រាន់សំរាប់ដោះស្រាយពេលវល់បុណ្យទាន ឬការកូនតែប៉ុណ្ណោះ។ ក្រៅពីមុខរបរធ្វើស្រែចំការមានបងប្អូនខ្លះមានមុខរបរលក់ ចាប់ហួយសំរាប់ផ្គត់ផ្គង់ជីវភាពបន្ថែម ប៉ុន្តែការលក់ដូររបស់គាត់មិនសូវជាកាក់កបប៉ុន្មានទេ ខ្លះអស់ដើម ដោយសារគេជំពាក់ច្រើនពេក វាមិនដូចនៅទីផ្សារឡើយ។

**វិបត្តិដែលធ្វើអោយលទ្ធភាពទិញដូររបស់គ្រួសារធ្លាក់ចុះ**

**១៨៨.** ក្រុមការងារបានសង្កេតឃើញថា រូបភាពនៃវិបត្តិដែលកើតមាននៅក្នុងសហគមន៍ ហាក់ដូចជាមានលក្ខណៈខុសគ្នាទៅនឹងតំបន់ភូមិភាគកណ្តាលនៃប្រទេស។ ករណីអាសន្នដែលកើតមានចំពោះសហគមន៍ទាំងនោះមានដូចជា:

- ការធ្វើស្រែរបស់ប្រជាពលរដ្ឋពឹងផ្អែកទៅលើធម្មជាតិទាំងស្រុង។
- ការធ្លាក់ចុះផលដែលទទួលបានពីធនធានធម្មជាតិដែលប្រជាជនពឹងផ្អែកប្រចាំថ្ងៃ។
- ពួកគាត់មានដីធំសំរាប់បង្កបង្កើនផល តែខ្វះចំណេះដឹង និងបច្ចេកទេសក្នុងការដាំ និងថែទាំ។ ដូច្នេះដើម្បីបង្គ្រប់សេចក្តីត្រូវការពួកគាត់ចូលព្រៃរកអនុផលព្រៃឈើបង្គ្រប់ជីវភាពបន្ថែម។
- ដីពុំសូវមានជីជាតិគួបផ្សំ និងចំណេះខាងផ្នែកកសិកម្មនៅមានកំរិតធ្វើអោយទិន្នផលស្រូវកាន់តែថយទៅៗ។

- ចំណែកឯបញ្ហាសុខភាពនៅតែជាបញ្ហាចោទមួយដ៏សំខាន់ ដែលប្រជាជននៅតំបន់នេះកំពុងតែប្រឈមមុខដោយសារសេវាសុខភាពនៅមានកំរិតទាបនៅឡើយ ។ ក្នុងករណីមានអ្នកណាម្នាក់ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ដែលមណ្ឌលសុខភាពតាមមូលដ្ឋានមិនមានលទ្ធភាពគ្រប់គ្រាន់ ទើបតម្រូវអោយពួកគាត់បង្ខំចិត្តបញ្ជូនអ្នកជំងឺនោះទៅមន្ទីរពេទ្យបង្អែកខេត្ត ដែលស្ថិតនៅចំងាយប្រហែល ៦០គ.ម ពីភូមិរបស់គាត់ ។ ដើម្បីដោះស្រាយវាលវិបត្តិទាំងនោះ ពួកគាត់បានប្រើគ្រប់មធ្យោបាយទាំងអស់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបានដូចជា: ខ្ចីបុលពីអ្នកដទៃ ដោយដាក់ស្រែបញ្ចាំ ចងការប្រាក់ លក់ស្រូវអង្ករ លក់គោ ក្របី ជាដើម ។ ទាំងនេះជាយុទ្ធសាស្ត្រមួយដើម្បីដោះទាល់នៅពេលដែលជួបប្រទះនូវវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារ ។

**សហគមន៍ព្រៃឈើ**

**១៨៩.** តាមការសិក្សាអង្កេតបានបង្ហាញអោយដឹងថា នៅក្នុងតំបន់នោះពុំទាន់មានសហគមន៍ព្រៃឈើនៅឡើយ ។ តាមប្រសាសន៍របស់លោក ខៀប សារ៉ន មេភូមិអូរទឹកថ្លា បានឱ្យដឹងថា ពួកគាត់មិនមានសហគមន៍ព្រៃឈើ ឬក៏បំរុងទុកសំរាប់កំណើនប្រជាពលរដ្ឋអ្វីដែរ ។ ពីព្រោះមិនមានអ្នកផ្តួចផ្តើម ឬមានជំនួយថវិកាពីខាងក្រៅទើបអាចបង្កើតបាន និងមាននិរន្តរភាពយូរអង្វែង ។ ដូចសហគមន៍មួយចំនួននៅពេលអ្នកផ្តល់ជំនួយគេដកទៅសហគមន៍លែងមានដំណើរការ សព្វថ្ងៃយើងខ្ញុំចង់បានដែរតែវាមិនអ្នកជំហរក្នុងភូមិ ។

**តំបន់គ្រប់គ្រងពិសេស**

**១៩០.** តាមការសាកសួរលោកមេភូមិ បានមានប្រសាសន៍ថានៅក្នុងភូមិនេះមិនតំបន់គ្រប់គ្រងពិសេសទេះ គឺមានតែព្រៃកប់ខ្មោចតែមួយប៉ុណ្ណោះគឺដីវាត្រែងនៅក្បែរភូមិ មានទំហំប្រមាណជា ១ហិកតា ។

**ហេតុប៉ះពាល់នៃការអនុវត្តគំរោងកសិ-ឧស្សាហកម្មទៅលើជីវភាពរស់នៅរបស់សហគមន៍ និងការទទួលយករបស់មូលដ្ឋានចំពោះគំរោងអភិវឌ្ឍន៍ :**

**១៩១.** យោងលើលទ្ធផលនៃការសិក្សាពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំស្រុក និងអាជ្ញាធរ ឃុំ-ភូមិ និងប្រជាជនសហគមន៍ដែលពាក់ព័ន្ធ បានបង្ហាញនូវទស្សនៈយល់ដឹងពីរផ្សេងពីគ្នា:

**១៩២.** ថ្នាក់ដឹកនាំភូមិ ឃុំ ស្រុក និងខេត្ត: ក្នុងករណីដែលរាជរដ្ឋាភិបាលធ្វើការប្រទានសិទ្ធិអោយក្រុមហ៊ុនធ្វើការវិនិយោគលើដំណាំកសិឧស្សាហកម្ម នោះនឹងនាំមកនូវផលប្រយោជន៍ពហុវិជ្ជមានច្រើនយ៉ាង ទាំងលើវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថាន ។ ទោះបីជាពួកគាត់មិនអាចផ្តល់ព័ត៌មានលំអិតពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងនេះក្តី តែពួកគាត់បានសំដែងសេចក្តីបារម្ភអំពីការធ្លាក់ចុះ និងបន្តបាត់បង់ធនធានព្រៃឈើ ដោយសារការ

Draft

ទន្រ្ទានយកដីធ្លីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាពតូចធំ និងសកម្មភាពប្រមូលផលព្រៃឈើដែលបាននឹងកំពុងបន្តយ៉ាងអាណាធិបតេយ្យក្នុងរូបភាពផ្ទុកលួចលាក់។

**១៩៣.** ជាការពិតណាស់ដែលថាការអភិវឌ្ឍន៍តែងតែមានចំណុចអវិជ្ជមាន និងការខ្វែងគំនិតគ្នារវាងវិនិយោគិនជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ឬរវាងវិនិយោគិន និងអាជ្ញាធរ ជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ទៅលើផលប្រយោជន៍រួមមួយដែលទាំងអស់គ្នាមានសិទ្ធិក្នុងការទទួលបាន ប៉ុន្តែទិសដៅ និងគោលបំណងរួមរបស់ពួកយើង គឺសំដៅធ្វើយ៉ាងណាដើម្បីទទួលបាននូវការអភិវឌ្ឍន៍នៅកម្ពុជាមួយដែលធានាបាននូវកំណើន និងការអភិវឌ្ឍន៍ ជាពិសេសសម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្ត្រ ដែលក្នុងនោះត្រូវពង្រឹង និងលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈអាចទទួលយកបានទាំងផ្នែកសង្គម-បរិស្ថាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ច។



Draft